អនុម័តនៅកិច្ចប្រជុំAMAFលើកទី៤០

ថ្ងៃទី១១ ខែ តុលា ២០១៨

ទីក្រុងហាណូយ, ប្រទេសវៀតណាម

# វិធីសាស្ត្ររបស់កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (AMAF) សម្រាប់ការបញ្ជ្រាបយេនឌ័រ ក្នុងវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ

ក្រុមការងារបច្ចេកទេសអាស៊ានលើវិស័យកសិកម្ម

និងការអភិវឌ្ឍន៍ស្រាវជ្រាវ (ATWGARD)

២០១៨

**Translated from the AMAF's Approach to Gender Mainstreaming in the Food, Agriculture and Forestry Sectors**

Disclaimer: This is an unofficial translation and provided for reference only.

AMAF's Approach to Gender Mainstreaming in the Food, Agriculture and Forestry Sectors, 2018.

To find the original version of the guideline please visit the ASEAN Secretariat website, https://asean.org/ or download at https://asean-crn.org/relevant-asean-guidelines-on-land-use/.

The translation has been produced with the support of the Climate Smart Land Use in ASEAN (CSLU) project, funded by the German Ministry for Economic Cooperation and Development and implemented by the Deutsche Gesellschaft für Internationale Zusammenarbeit (GIZ).

implemented by:

In cooperation with

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ត្រូវបានបង្កើតឡើងនៅថ្ងៃទី ៨ ខែសីហា ឆ្នាំ១៩៦៧។
រដ្ឋជាសមាជិកនៃសមាគននេះរួមមាន ប្រទេសប្រ៊ុយនេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និង វៀតណាម។

សម្រាប់សំនួរ,សូមទាក់ទងមក៖
លេខាធិការដ្ឋានអាស៊ាន
ផ្នែកទំនាក់ទំនងសហគមន៍៧០A Jalan Sisingamangaraja
ទីក្រុងហ្សាកាតា១២១១០
ប្រទេសឥណ្ឌូនេស៊ី
លេខទូរស័ព្ទ : (62 21) 724-3372, 726-2991 Fax : (62 21) 739-8234, 724-3504 E-mail :public.div@asean.org
ព័ត៌មានទូទៅលើប្រព័ន្ធអនឡាញអាស៊ាននៅគេហទំព័រអាស៊ាន៖ www.asean.org Catalogue-inPublication Data

វិធីសាស្ត្ររបស់AMAF សម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងផ្នែកចំណីអាហារ កសិកម្ម និងព្រៃឈើ
ទីក្រុងហ្សាកាតា៖ លេខាធិការដ្ឋានអាស៊ាន ២០១៨

# បញ្ជីពាក្យកាត់

| | |
|---|---|
| ACW | គណៈកម្មាធិការស្ត្រីអាស៊ាន (ASEAN Committee on Women) |
| AMAF | កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (ASEAN Ministers Meeting on Agriculture and Forestry) |
| AMS | រដ្ឋសមាជិកអាស៊ាន (ASEAN Member States) |
| ASCC | សហគមន៍វប្បធម៌សង្គមនិងវប្បធម៌អាស៊ាន (ASEAN Socio-Cultural Community) |
| ASEAN | សមាគមអាស៊ីអាគ្នេយ៍ (The Association of Southeast Asian Nations) |
| ASOF | មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីព្រៃឈើ (ASEAN Senior Officials on Forestry) |
| ASWGL | ក្រុមការងារតំបន់អាស៊ានស្តីពីបសុសត្វ (ASEAN Sectoral Working Group on Livestock) |
| ASWGC | ក្រុមការងារតាមវិស័យលើផលិតកម្មដំណាំរបស់អាស៊ាន (ASEAN Sectoral Working Group on Crops) |
| ASWGFi | ក្រុមការងារតំបន់អាស៊ានស្តីពីជលផល (ASEAN Sectoral Working Group on Fisheries) |
| ATWGARD | ការស្រាវជ្រាវនិងអភិវឌ្ឍន៍វិស័យកសិកម្ម (Agricultural Research and Development) |
| AWGCC | ក្រុមការងារអាស៊ានស្តីពីការប្រែប្រួលអាកាសធាតុ (ASEAN Working Group on Climate Change) |
| COP | សន្និសីទរបស់ភាគី ( Conference of the Parties) |
| CSA | កសិកម្មឆ្លាតវៃអាកាសធាតុ (Climate Smart Agriculture) |
| FAO | អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ (The Food and Agriculture Organization of the United Nations) |
| FES | ហ្វ្រីដិច-អ៊ីប៊ឺត-ស្ទ្រីហ្វុង (Friedrich-Ebert-Stiftung) |
| FCPF | អង្គការភាពជាដៃគូកាបូនព្រៃឈើ (Forest Carbon Partnership Facility) |
| GSVC | ខ្សែសង្វាក់តម្លៃយេនឌ័រ (Gender-Sensitive Value Chain) |
| HPA | ផែនការសកម្មភាពហាណូយ (Hanoi Plan of Action) |
| IDS | វិទ្យាស្ថានសិក្សានៃការអភិវឌ្ឍន៍ (Institute of Development Studies) |
| NTFP | ផលិតផលមិនមែនសមិទ្ធផលព្រៃឈើ (Non-Timber Forest Product) |
| R-PP | សំណើរៀបចំការត្រៀមខ្លួន (Readiness Preparation Proposal) |
| SPA | ផែនការសកម្មភាពយុទ្ធសាស្ត្រ (Strategic Plan of Action) |
| SSF | ជលផលខ្នាតតូចប្រកបដោយនិរន្តរភាព (Sustainable Small-Scale Fisheries) |
| UN | អង្គការសហប្រជាជាតិ (United Nations) |
| UNFCCC | អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UN Framework Convention on Climate Change) |
| UNDRIP | សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម (UN Declaration on the Rights of Indigenous Peoples) |
| VAP | កម្មវិធីសកម្មភាពទីក្រុងវៀងចន្ទន៍ (Vientiane Action Programme) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organization) |

# បុព្វកថា

វិធីសាស្ត្ររបស់កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (AMAF) សម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើត្រូវបានបំពេញ ដោយក្រុមការងារបច្ចេកទេសអាស៊ានលើការស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យកសិកម្ម(ATWGARD) ដោយមានការគាំទ្រពីក្រុមការងារអាស៊ានលើវិស័យបសុសត្វ ដំណាំ និងជលផល និងមន្ត្រីជាន់ខ្ពស់អាស៊ានលើការងារព្រៃឈើ (ASOF) និងគណកម្មាធិការអាស៊ានលើការងារស្ត្រី (ACW)។

វិធីសាស្ត្ររបស់កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (AMAF) សម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងផ្នែកចំណីអាហារ កសិកម្ម និងព្រៃឈើត្រូវបានត្រូវបាន កំណត់ថាជាវិធានការសាធារណៈដែលអនុវត្តទស្សនៈយេនឌ័រដែលជាលទ្ធផលជះឥទ្ធិពលដល់អាកប្បកិរិយារបស់អ្នកពាក់ព័ន្ធផ្សេងៗគ្នា (ក្នុងចំណោមអ្នកផលិតកសិករ និងនិយតករដទៃទៀត)។ គោលនយោបាយយេនឌ័រគ្រប ដណ្តប់លើផ្នែកសំខាន់ៗដែលត្រូវបញ្ចូលទៅក្នុងសំណុំគោលនយោបាយនិងកម្មវិធីនានាដើម្បីជានាថាស្ត្រីធ្វើការនៅក្នុងវិស័យចំណីអាហារកសិកម្មនិងព្រៃឈើនៅក្នុងតំបន់អាស៊ានត្រូវបានផ្តល់អំណាច។

ដោយទទួលស្គាល់ថាវិសមភាពយេនឌ័របានជ្រាបចូលក្នុងវិស័យចំណីអាហារកសិកម្មនិងព្រៃឈើហើយថា គោលនយោបាយនិងក្របខ័ណ្ឌសាធារណៈផ្តល់នូវផលជះយេនឌ័រយ៉ាង សំខាន់លើវិស័យ ទាំងបី។វិធីសាស្ត្ររបស់កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (AMAF) មានគោលបំណងក្នុងការកំណត់នូវអនុសាសន៍ដែលប្រើជាការណែនាំយោងសម្រាប់រដ្ឋជាសមាជិកអាស៊ាន (AMS) ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅ ក្នុងវិស័យចំណីអាហារកសិកម្មនិងព្រៃឈើ។ វិធីសាស្ត្ររបស់ កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (AMAF) មិនមានបំណងធ្វើជាសេចក្តីថ្លែងការណ៍ពេញលេញឬភ្ជាប់នឹងយេនឌ័រទេ។ វិធីសាស្ត្ររបស់AMAF នឹងជួយបង្កើនការយល់ដឹងរបស់រដ្ឋជាសមាជិកអំពីសារៈសំខាន់នៃគោលនយោបាយយេនឌ័រនៅក្នុងវិស័យម្ហូបអាហារ កសិកម្ម និងព្រៃឈើ ដោយមានគោលបំណងជំរុញការអភិវឌ្ឍន៍នៃការអនុវត្តល្អបំផុត និងបង្កើនកិច្ចសហប្រតិបត្តិការរវាងប្រទេសជាសមាជិកអាស៊ាន។

វិធីសាស្ត្ររបស់ កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (AMAF)សម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យចំណីអាហារកសិកម្មនិងព្រៃឈើដែលជាឯកសារសាធារណៈ នឹងក្លាយជាឯកសារយោងដោយសារ ការស្រាវជ្រាវនិងអភិវឌ្ឍន៍វិស័យកសិកម្ម (ATWGARD) នឹងធ្វើបច្ចុប្បន្នភាពវាជាញឹកញាប់ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនិងការ អភិវឌ្ឍន៍នៅក្នុងតំបន់អាស៊ាន និងការអនុវត្តអន្តរជាតិ/តំបន់ល្អបំផុត។

វិធីសាស្ត្ររបស់AMAFសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យចំណីអាហារកសិកម្ម និងព្រៃឈើត្រូវបានរដ្ឋមន្ត្រីក្រសួងកសិកម្មនិងព្រៃឈើអាស៊ាន (AMAF) អនុម័តនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ លើកទី ៤០ ឆ្នាំ ២០១៨ នៅទីក្រុងហាណូយប្រទេសវៀតណាម។

# តារាងមាតិកា


បញ្ជីពាក្យកាត់ ...... 4
បុព្វកថា ...... 5
1. សេចក្តីផ្តើម ...... 8
1.1 សមភាពយេនឌ័រក្នុងតំបន់អាស៊ាន ...... 8
1.2 ស្ត្រីក្នុងវិស័យម្ហូបអាហារ កសិកម្ម និងព្រៃឈើក្នុងតំបន់អាស៊ាន ...... 8
2. គោលបំណង ...... 9
3. វិធីសាស្ត្រនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (AMAF) សម្រាប់ការបញ្ជ្រាបយេនឌ័រ ...... 9
3.1 សេចក្តីថ្លែងការគោលនយោបាយរបស់ AMAF ...... 9
3.2 កិច្ចសហប្រតិបត្តិការវិស័យម្ហូបអាហារ កសិកម្ម និងព្រៃឈើ ...... 10
3.2.1 វិស័យចិញ្ចឹមសត្វ ...... 10
3.2.2 ដំណាំ ...... 12
3.2.3 វិស័យជលផល និងវារីវប្បកម្ម ...... 13
3.2.4 ព្រៃឈើ ...... 14
3.2.5 ការប្រែប្រួលអាកាសធាតុ ...... 15
3.2.6 សន្តិសុខស្បៀង និងអាហាររូបត្ថម្ភ ...... 17
3.2.7 ការបញ្ចូលយេនឌ័រទៅក្នុងខ្សែច្រវាក់ផលិតកម្មចំណីអាហារ កសិកម្ម និងព្រៃឈើ ...... 18
4. យុទ្ធសាស្ត្រថ្នាក់តំបន់ និងផែនការសកម្មភាព ...... 19
4.1 ការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ ...... 19
4.2ក្របខ័ណ្ឌសម្រាប់យុទ្ធសាស្ត្រសម្រាប់បញ្ជ្រាបយេនឌ័រក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ ...... 19
4.2.1 វិធីសាស្ត្រ និងការគាំទ្រ ...... 19
4.2.2 ការកសាងសមត្ថភាព ...... 20
4.2.3 ក្របខ័ណ្ឌស្ថាបន ...... 20
4.2.4 ការកសាង និងពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រ ...... 20
4.2.5 ព័ត៌មាន ការទំនាក់ទំនង និងការផ្សព្វផ្សាយ ...... 21
4.2.6 ការស្រាវជ្រាវ នវានុវត្ត និងបច្ចេកវិទ្យា ...... 21
5. ដំណើរអនុវត្ត ...... 21
ឯកសារយោង ...... 22
ឧបសម្ព័ន្ធទី ១៖ អន្តរាគមន៍យេនឌ័រដែលត្រូវបានផ្តល់អនុសាសន៍នៅក្នុងផ្នែក SPAs ...... 23
SPAsខាងក្រោមត្រូវបានពិនិត្យដើម្បីបង្កើតអនុសាសន៍សម្រាប់វិធីសាស្ត្រ ...... 23
ផែនការយុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានលើវិស័យម្ហូបអាហារ កសិកម្ម និងព្រៃឈើ ...... 23
(២០១៦-២០២៥) ...... 23
ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍វិស័យកសិកម្ម ...... 24
២០១៦-២០២០ ...... 24
ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហ ប្រតិបត្តិការអាស៊ានក្នុងវិស័យបសុសត្វ ២០១៦-២០២០ ...... 25
ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហប្រតិបត្តិការ ...... 26
អាស៊ានក្នុងវិស័យដំណាំ ...... 26

២០១៦-២០២០ ..... 26
ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហប្រតិបត្តិ..... 27
ការអាស៊ានក្នុងវិស័យជលផល ..... 27
២០១៦-២០២០ ..... 27
ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ច..... 28
សហប្រតិបត្តិការអាស៊ានក្នុងវិស័យព្រៃឈើ ..... 28
២០១៦-២០២៥..... 28
ក្របខណ្ឌសន្តិសុខស្បៀងរួមរបស់អាស៊ាន(AIFS) និងផែនការសកម្មភាពយុទ្ធសាស្ត្រ ..... 29
លើសន្តិសុខស្បៀងក្នុងតំបន់អាស៊ាន (២០១៥-២០២០)..... 29

# 1.សេចក្តីផ្តើម

## 1.1 សមភាពយេនឌ័រក្នុងតំបន់អាស៊ាន

ក្រោមបរិបទអាស៊ានវិសមភាពយេនឌ័រត្រូវបានបង្កើតឡើងដោយសង្គមក្នុងវិមាត្រជាច្រើនដែលមិនត្រឹមតែរារាំងដល់ការអភិវឌ្ឍន៍របស់មនុស្សប៉ុណ្ណោះទេថែមទាំងធ្វើឱ្យមានទំនាស់និងភាពងាយរងគ្រោះក្នុងសង្គមផងដែរ។វិសមភាពយេនឌ័រឆ្លុះបញ្ចាំងថាស្ត្រីទទួលបានអំណាចមានកំណត់នៅក្នុងវិស័យជាច្រើនក្នុងជីវិត ដូចជាវិសមភាពក្នុងលទ្ធភាពទទួលបានសម្ភារមូលដ្ឋាន វិសមភាពវិជ្ជាជីវៈភាពជាម្ចាស់និងវិសមភាពក្នុងគ្រួសារដែលធ្វើឱ្យស្ត្រីធ្លាក់ក្នុងវិបត្តិនៃភាពងាយរងគ្រោះ។យោងតាមនិយមន័យសមភាពយេនឌ័រដែលបានកំណត់ថាជា“សិទ្ធិស្មើគ្នាការទទួលខុសត្រូវនិងឱកាសរបស់ស្ត្រីបុរសនិងក្មេងស្រីនិងក្មេងប្រុស”(UN ២០០១)។ រដ្ឋាភិបាលនៃបណ្តាលប្រទេសអាស៊ានបានខិតខំប្រឹងប្រែងក្នុងការធ្វើសមាហរណកម្មបញ្ហាយេនឌ័រទៅក្នុងការអភិវឌ្ឍន៍ផ្សេងៗគ្នាតាមរយៈកំណែទម្រង់ច្បាប់និងគោលនយោបាយយេនឌ័រជាក់លាក់រួមមានការបង្កើតការិយាល័យរដ្ឋាភិបាលជាក់លាក់ដែលជាយន្តការចម្បងក្នុងការជំរុញឋានៈស្ត្រីនិងសមភាពយេនឌ័រ។

ក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ានលើកទី ៣១ នៅប្រទេសហ្វីលីពីនប្រមុខរដ្ឋឬរដ្ឋាភិបាលអាស៊ានបានអនុម័ត“សេចក្តីប្រកាសអាស៊ានស្តីពីការអនុវត្តប្រកបដោយការទទួលខុសត្រូវយេនឌ័រនៃចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ ២០២៥ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព”។ពួកគេបានប្រកាសពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការធានាឱ្យបាននូវភាពប្រាកដប្រជានៃក្របខណ្ឌអាស៊ានដែលផ្តោតលើប្រជាជននិងមជ្ឈមណ្ឌលប្រជាជនដែលស្ត្រីនិងក្មេងស្រីទាំងអស់អាចសម្រេចបាននូវសក្តានុពលរបស់ពួកគេ។

ជាលទ្ធផលជាមួយនឹងការធ្វើសមាហរណកម្មតំបន់និងសមត្ថភាពទីផ្សារដែលមានប្រជាជនជាង ៦០០ លាននាក់បង្ហាញពីឱកាសដ៏ធំរដ្ឋាភិបាលនៃប្រទេសអាស៊ានគួរតែពង្រឹងសមត្ថភាពស្ត្រីពង្រីកលទ្ធភាពទទួលបាននិងគាំទ្រការរួមចំណែករបស់ពួកគេចំពោះវិស័យសេដ្ឋកិច្ចផ្លូវការ។ការកើនឡើងនៃការចូលរួមផ្នែកសេដ្ឋកិច្ចផ្លូវការនឹងធ្វើឱ្យស្ត្រីមានលទ្ធភាពទទួលបានធនធានឱកាសនិងមធ្យោបាយងាយស្រួលស្មើគ្នាក្នុងនាមជាសមភាគីបុរសរបស់ពួកគេដែលនឹងនាំមកនូវការពង្រឹងអំណាចរបស់ស្ត្រីនិងពង្រួញគម្លាតយេនឌ័រ។

នៅក្នុងការសិក្សាថ្មីមួយស្តីពី“ផលប៉ះពាល់យេនឌ័រនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន”ដែលធ្វើឡើងដោយការិយាល័យប្រចាំតំបន់របស់អង្គការសហប្រជាជាតិសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិកនិងហ្វ្រីដិច-អ៊ីប៊ឺត-ស្ទីហ្វុង (FES) សហការជាមួយលេខាធិការដ្ឋានអាស៊ាននិងដោយមានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលីលទ្ធផលបានបង្ហាញថាបើគ្មានគោលនយោបាយនិងអន្តរាគមន៍ជាកម្មវិធីច្បាស់លាស់ទេទំនងជាវិស័យធំៗរបស់ស្ត្រីនឹងត្រូវបានដកចេញពីផលប្រយោជន៍ផ្ទាល់នៃការជំរុញពាណិជ្ជកម្មការវិនិយោគនិងការធ្វើសមាហរណកម្មកម្លាំងជំនាញ។ការស្រាវជ្រាវបានរកឃើញថាវិធានការសេរីភាវូបនីយកម្មនឹងជះឥទ្ធិពលមិនស្មើគ្នាដោយសារតែវិសមភាពដែលមានស្រាប់រួមមានមូលដ្ឋានលើប្រាក់ចំណូលយេនឌ័រភូមិសាស្ត្រឬជនជាតិភាគតិចលទ្ធភាពទទួលបានធនធាននិងភាពជាម្ចាស់កម្មសិទ្ធិនឹងកំណត់លទ្ធភាពទទួលបានដោយសក្តានុពលរបស់ស្ត្រីក្នុងការធ្វើពាណិជ្ជកម្ម។

## 1.2 ស្ត្រីក្នុងវិស័យម្ហូបអាហារ កសិកម្ម និងព្រៃឈើក្នុងតំបន់អាស៊ាន

កសិកម្មគឺជាវិស័យនាំចេញដ៏សំខាន់មួយនៅក្នុងប្រទេសសមាជិកអាស៊ានចំនួន ៦ រួមមានកម្ពុជាឡាវមីយ៉ាន់ម៉ាថៃឥណ្ឌូនេស៊ីនិងវៀតណាម។ខណៈដែលប្រទេសកសិកម្មធំៗមួយចំនួនកំពុងស្ថិតក្នុងដំណាក់កាលផ្សេងៗគ្នានៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមមានភាពស្រដៀងគ្នាគួរឱ្យកត់សម្គាល់លើបញ្ហាប្រឈមដែលស្ត្រីប្រឈមមុខក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ។ស្ត្រីជិត ៧៥ ភាគរយនៅកម្ពុជាប្រកបមុខរបរកសិកម្មស្ត្រី ៦៩ ភាគរយជាកសិករនៅមីយ៉ាន់ម៉ា ៤៨ ភាគរយនៅវៀតណាមនិង ៥១ភាគរយនៅប្រទេសឡាវ។

ទោះបីជាមានកំណើនឧស្សាហកម្មក៏ដោយអនុវិស័យកសិកម្មនិងកសិ-ឧស្សាហកម្មដូចជា បសុសត្វ និងព្រៃឈើភាគច្រើនមានស្ត្រីជាអ្នកធ្វើការ។ស្ត្រីចូលរួមក្នុងកម្រិតស្មើគ្នានៃខ្សែចង្វាក់តម្លៃប៉ុន្តែមិនចាំបាច់ឈានដល់កម្រិតស្មើគ្នាផ្នែកនាំចេញទេ។

ដោយសារវិស័យចំណីអាហារ

កសិកម្មនិងព្រៃឈើមានភាពងាយរងគ្រោះយ៉ាងខ្លាំងទៅនឹងបំរែបំរួលអាកាសធាតុនិងការប្រែប្រួលអាកាសធាតុតាមទស្សនៈយេនឌ័រស្ត្រីនិងយុវជនងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ។កសិករជាស្ត្រីប្រឈមនឹងបញ្ហាជាច្រើនក្នុងការផ្លាស់ប្តូរលើសពីកម្រិតនៃការចិញ្ចឹមជីវិតដើម្បីទទួលបានទីផ្សារនាំចេញនៅក្នុងប្រទេសសមាជិកអាស៊ាន។កម្រិតនៃភាពក្រីក្រនៅតាមជនបទគឺខ្ពស់ហើយស្ត្រីមានបរិមាណការងារពលកម្មមិនស្មើគ្នាទាំងក្នុងគ្រួសារនិងនៅកសិដ្ឋាន។

ទោះបើជាការចូលរួមយ៉ាងសំខាន់របស់ស្ត្រីក្នុងវិស័យកសិកម្មក៏ដោយកម្មសិទ្ធិដីធ្លីនិងកម្មសិទ្ធិលើទ្រព្យសម្បត្តិផលិតកម្មផ្សេងទៀតនៅតែមានភាគច្រើនជារបស់បុរស។ការចូលទៅកាន់ទីផ្សារមិនបានល្អនិងការពឹងផ្អែកខ្លាំងលើឈ្មួញកណ្តាលធ្វើឱ្យស្ត្រីពិបាកក្នុងការចូលទីផ្សារខាងក្រៅនិងទទួលបានតម្លៃសមរម្យសម្រាប់ផលិតផលរបស់ពួកគេ។ការប្ញកសរុបនេះគឺជាការពិតដែលថាឥណទានសម្រាប់គោលបំណងកសិកម្មពិបាកនឹងទទួលបានសម្រាប់ស្ត្រីដោយសារតែពួកគេខ្វះភាពជាម្ចាស់កម្មសិទ្ធទ្រព្យសម្បត្តិនិងកម្រិតអប់រំទាបនៅក្នុងប្រទេសសមាជិកអាស៊ានមួយចំនួន។

## 2. គោលបំណង

វិធីសាស្ត្ររបស់AMAF សម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យម្ហូបអាហារ កសិកម្ម និងព្រៃឈើត្រូវបានបង្កើតឡើងដើម្បីជួយសមាជិកអាស៊ានទាំងអស់៖

- ផ្តល់សេចក្តីណែនាំក្នុងការយល់ដឹងនិងការណែនាំអំពីគោលនយោបាយនិងកម្មវិធីឆ្លើយតបយេនឌ័រនៅថ្នាក់តំបន់
- លើកកម្ពស់និងគាំទ្រចំពោះសមភាពយេនឌ័រនៅក្នុងគោលនយោបាយ កម្មវិធី ប្រព័ន្ធ និងរចនាសម្ព័ន្ធចំណីអាហារកសិកម្មនិងព្រៃឈើនៅថ្នាក់តំបន់និងថ្នាក់ជាតិ។
- ពង្រឹងនិងកសាងសមត្ថភាពអ្នកធ្វើគោលនយោបាយ អ្នកធ្វើការនៅតាមមូលដ្ឋាន និងកសិករអំពីវិធីសាស្ត្រសស្នើគ្នាមស្របដើម្បីបញ្ចូលយេនឌ័រក្នុងវិស័យកសិកម្មនឹងការប្រែប្រួលអាកាសធាតុ
- លើកកម្ពស់ការស្រាវជ្រាវសមភាពយេនឌ័រដែលគាំទ្រដល់បច្ចេកវិទ្យាកសិកម្មឆ្លាតវៃតាមអាកាសធាតុ។

វិធីសាស្ត្ររបស់AMAF សម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើគឺជាកិច្ចខិតខំប្រឹងប្រែងដែលមិនជាប់ពាក់ព័ន្ធដើម្បីជួយក្នុងដំណើរការបង្កើតកិច្ចសហប្រតិបត្តិការនិងការធ្វើសមាហរណកម្មយេនឌ័រនៅក្នុងតំបន់ដោយដើរតួជាសេចក្តីណែនាំយោងរួមសម្រាប់កិច្ចសហប្រតិបត្តិការនាពេលអនាគតដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យចំណីអាហារកសិកម្មនិងព្រៃឈើនៅក្នុងតំបន់អាស៊ាន។វិធីសាស្ត្ររបស់AMAF ផ្តោតការយកចិត្តទុកដាក់លើបរិបទនិងស្ថានភាពក្នុងតំបន់និងថ្នាក់ជាតិ។

## 3. វិធីសាស្ត្រនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (AMAF) សម្រាប់ការបញ្ជ្រាបយេនឌ័រ

### 3.1 សេចក្តីថ្លែងការគោលនយោបាយរបស់ AMAF

ដោយកត់សម្គាល់ថាសមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រីនិងក្មេងស្រីទាំងអស់គឺជាចំណុចស្នូលនៃរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពហើយថាសមភាពយេនឌ័រត្រូវបានទទួលស្គាល់និងបញ្ជាក់ថាជាបុរេលក្ខខណ្ឌសម្រាប់ភាពប្រាកដប្រជានៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព AMAF បានបញ្ជាក់ជាថ្មីម្តងទៀតអំពីតម្រូវការក្នុងការបញ្ជ្រាបទស្សនៈនិងការវិភាគយេនឌ័រដែលរួមមានគោលដៅសកម្មភាពនិងការវិនិយោគក្នុងការបង្កើតនិងការអនុវត្តគោលនយោបាយផែនការនិងកម្មវិធីនៃវិស័យចំណីអាហារកសិកម្មនិងព្រៃឈើទាំងអស់នៅ

ក្នុងតំបន់អាស៊ាន។ទាំងនេះត្រូវគ្នាទៅនឹងការប្តេជ្ញាចិត្តដែលមានចែងនៅក្នុងសេចក្តីប្រកាសអាស៊ានស្តីពីការអនុវត្តឆ្លើយតបយេនឌ័រនៃចក្ខុវិស័យសហគមន៍អាស៊ាន ២០២៥ ។

កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (AMF) បានលើកទឹកចិត្តឱ្យមានការវិនិយោគបន្ថែមទៀតដើម្បីបិទបញ្ចប់គម្លាតធនធានសម្រាប់ការសម្រេចបាននូវសមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រីនិងក្មេងស្រីទាំងអស់។

កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់(AMF) បានយល់ស្របដើម្បីលើកកម្ពស់ការទទួលបានសិទ្ធិស្មើគ្នានិងការចូលរួមពេញលេញរបស់ស្ត្រីនៅក្នុងស្ថាប័ននិងយន្តការធ្វើការសម្រេចចិត្តដែលពាក់ព័ន្ធទៅនឹងការអនុវត្តគោលដៅនិងទិសដៅទាំងអស់នៃរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងផែនការយុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកចំណីអាហារកសិកម្មនិងព្រៃឈើ (២០១៦-២០២៥)រួមទាំងគោលនយោបាយផែនការនិងការបង្កើតកម្មវិធីការអនុវត្តនិងការត្រួតពិនិត្យនិងវាយតម្លៃសម្រាប់អនុវិស័យចិញ្ចឹមសត្វ ដំណាំផលផលនិងព្រៃឈើ។

កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់(AMF) លើកទឹកចិត្តយ៉ាងខ្លាំងដល់ស្ថាប័នពាក់ព័ន្ធរបស់អាស៊ានដើម្បីលើកកម្ពស់ការអនុវត្តវិធីសាស្ត្ររបស់AMAFទាក់ទងនឹងវិស័យចំណីអាហារកសិកម្មនិងព្រៃឈើ។

## 3.2 កិច្ចសហប្រតិបត្តិការវិស័យម្ហូបអាហារ កសិកម្ម និងព្រៃឈើ

បញ្ហាយេនឌ័ររួមដែលត្រូវពិចារណាក្នុងវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើរួមមាន៖

- ធានាឱ្យមានការចូលរួមដោយស្មើភាពគ្នារវាងស្ត្រីនិងបុរសនៅក្នុងរាល់ការពិភាក្សាគោលនយោបាយសកម្មភាពកសាងសមត្ថភាពនិងការចូលរួមគ្រប់សកម្មភាពថ្នាក់ជាតិនិងថ្នាក់តំបន់។
- ធានាការប្រមូលទិន្នន័យយេនឌ័រសម្រាប់គ្រប់ការប្រមូលទិន្នន័យទាំងអស់ក្នុងកំឡុងពេលនៃការរៀបចំការអនុវត្តនិងដំណាក់កាលត្រួតពិនិត្យនិងវាយតម្លៃរាល់គម្រោងសកម្មភាពទាំងអស់។/
- ផ្តល់ឱកាសដល់ស្ត្រីក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុផ្សេងៗគ្នាដូចជាគណនីទានប្រាក់សន្សំការផ្ញើរប្រាក់និងគម្រោងធានារ៉ាប់រងដើម្បីផ្តល់ឱ្យពួកគេនូវឱកាសដើម្បីពង្រីកគំនិតផ្តួចផ្តើមចំណីអាហារកសិកម្មនិងព្រៃឈើ។
- លើកទឹកចិត្តនិងសម្រួលដល់ការទទួលបានការអប់រំរបស់ស្ត្រីក៏ដូចជាការចូលរួមរបស់ពួកគេក្នុងការបណ្តុះបណ្តាលសំដៅលើកកម្ពស់ជំនាញទីផ្សារការធ្វើពាណិជ្ជកម្មនិងជំនាញរបស់ស្ត្រី។
- ផ្តល់ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដើម្បីពង្រឹងនិងពង្រីកសម្លេងនិងភាពជាអ្នកដឹកនាំរបស់ស្ត្រី។
- ធានាឱ្យមានការចូលរួមស្មើភាពគ្នារវាងស្ត្រីនិងបុរសនៅក្នុងដំណើរការសម្រេចចិត្តទាំងអស់។
- សំរបសំរួលជាមួយស្ថាប័នអាស៊ានដទៃទៀតដើម្បីគាំទ្រសម្រាប់ការបញ្ជ្រាបយេនឌ័រ។

### 3.2.1 វិស័យចិញ្ចឹមសត្វ

អនុវិស័យបសុសត្វរួមចំណែកយ៉ាងសំខាន់ដល់ទិន្នផលជាតិការងារនិងសន្តិសុខស្បៀងនៅក្នុងតំបន់អាស៊ានទោះបីជាសារៈសំខាន់របស់វាមានភាពខុសគ្នានៅទូទាំងបណ្តាលប្រទេសសមាជិកអាស៊ានក៏ដោយ។ ក្រោមកិច្ចសហប្រតិបត្តិការអាស៊ានលើចំណីអាហារកសិកម្មនិងព្រៃឈើក្រុមការងារអាស៊ានស្តីពីវិស័យបសុសត្វ

(ASWGL)ត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវយន្តការមួយក្នុងការបង្កើតស្តង់ដារអាស៊ានក្នុងការវិស័យបសុសត្វសម្រាប់ការចាក់វ៉ាក់សាំង ការអនុវត្តការចិញ្ចឹមសត្វល្អ និងសកម្មភាពពាក់ព័ន្ធផ្សេងទៀតនៅក្នុងអនុវិស័យនេះ។ នៅអាស៊ានផលិតផលបសុសត្វសំខាន់គឺបសុបក្សីនិងសាច់ជ្រូក។ ទោះបីជាកំណើនផលិតកម្មមានភាពឆាប់រហ័សក៏ដោយក៏តំបន់ទាំងមូលគឺជាអ្នកនាំចូលទាំងសាច់និងផលិតផលទឹកដោះគោ។ មានតែប្រទេសថៃមួយគត់ដែលជាអ្នកនាំចេញសាច់ ជាពិសេសប)សុបក្សី ។

ចំពោះករណីសាច់ ការនាំចូលមានកម្រិតតិចតួចប៉ុណ្ណោះ គឺប្រហែល ៥% ទោះបីជាមានការកើនឡើងនៃការប្រើប្រាស់សរុបក៏ដោយ។ ការរីកចម្រើននៃឧស្សាហកម្មបសុសត្វក៏បាននាំមកនូវការនាំចូលចំណីសត្វខ្ពស់ផងដែរ។ ការចូលរួមចំណែកនៃវិស័យកសិកម្មក្នុងទិន្នផលជាតិកំពុងធ្លាក់ចុះក្នុងបណ្តាលប្រទេសមួយចំនួនក្នុងតំបន់អាស៊ានដែលមានការរីកចំរើនខ្លាំង ផ្ទុយមកវិញការចូលរួមចំណែកនៃវិស័យបសុសត្វក្នុងវិស័យកសិកម្មកំពុងកើនឡើង។

នៅពេលដែលការផលិតនិងការកែច្នៃខ្នាតធំៗកំពុងលេចធ្លោនៅក្នុងប្រទេសដែលមានការរីកចំរើនខ្លាំង ការចិញ្ចឹមបសុសត្វខ្នាតតូចនៅតែគ្របដណ្តប់នៅក្នុងបណ្តាលប្រទេសរដ្ឋជាសមាជិកអាស៊ាន (AMS) ដែលមិនសូវមានអភិវឌ្ឍន៍ដែលពួកវាដើរតួយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងអាហាររូបត្ថម្ភនិងសមភាពយេនឌ័រ។

វាត្រូវបានគេប៉ាន់ប្រមាណថាប្រហែល ជា៥០ ទៅ ៨០ ភាគរយនៃផលិតកម្មបសុសត្វសរុបនៅក្នុងប្រទេសសមាជិកអាស៊ានអាចត្រូវបានចូលរួមចំណែកពីអ្នកចិញ្ចឹមខ្នាតតូច។ ភាគរយនេះប្រែប្រួលក្នុងចំណោម និងរវាងប្រទេសអាស្រ័យលើកត្តាជាច្រើន។ នៅកម្រិតកសិករតូចប្រព័ន្ធផលិតកម្មភាគច្រើនជាលក្ខណៈគ្រួសារ ឬជាសហគ្រាសដែលផ្តោតលើទីផ្សារខ្នាតតូចៗ ដែលភាគច្រើនពឹងផ្អែកលើធនធានចំណីនិងកម្លាំងពលកម្មគ្រួសារ។ ប្រព័ន្ធនេះជារឿយៗមានផលិតកម្មទាប។ ស្ត្រីដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ចំណីរ ការសម្អាតនិងការគ្រប់គ្រងបសុសត្វចិញ្ចឹម ជាពិសេសជ្រូកមាន់ និងសត្វពាហនៈតូចៗក្រៅពីធ្វើសកម្មភាពប្រចាំថ្ងៃដែលទាក់ទងនឹងតួនាទីរបស់ពួកគេនៅក្នុងគ្រួសារ។ មិនដូចតំបន់ផ្សេងទៀតទេ ស្ត្រីនៅតំបន់អាស៊ីអាគ្នេយ៍ក៏ចូលរួមក្នុងការលក់ផលិតផលបសុសត្វជាពិសេសសាច់ស្រស់។ បុរសភាគច្រើនចូលរួមទិញសម្ភារកសិកម្ម លក់សត្វ និងផលិតផលបសុសត្វនិងគ្រប់គ្រងសត្វធំៗ ដូចជាគោនិងក្របី។ ការចូលរួមរបស់បុរសកើនឡើងជាមួយនឹងការកើនឡើងនៃកសិកម្មខ្នាតធំ និងទំហំហ្វូងសត្វ។

បញ្ហាយេនឌ័រទាក់ទងទៅនឹងវិស័យបសុសត្វជុំវិញតំបន់អាស៊ានមានភាពស្រដៀងគ្នាភាគច្រើន ដោយអាស្រ័យលើវប្បធម៌ និងប្រពៃណីយ៍។ បញ្ហាប្រឈមសំខាន់ៗដែរស្ត្រីប្រឈមក្នុងផលិតកម្ម និងប្រព័ន្ធទីផ្សាររួមមាន ប៉ុន្តែមិនកម្រិតដល់៖

- ការទទួលបានសេវាផ្សព្វផ្សាយ ឥណទាន បច្ចេកទេស បណ្តុះបណ្តាល និងព័ត៌មាននៅមានកម្រិត
- កង្វះការគ្រប់គ្រងក្នុងការសម្រេចចិត្តនៅក្នុងគ្រួសារ សហគមន៍ និងកម្រិតស្ថាប័នក្នុងតំបន់
- ការគ្រប់គ្រងចំណូរ និងទ្រព្យសម្បត្តិ និងការបាត់បង់ចំណូលភាគច្រើនទៅបុរស ដែលមិនបានវិនិយោគត្រឡប់មកគ្រួសារវិញ
- ការទទួលបាន គ្រប់គ្រង និងកម្មសិទ្ធលើធនធានធម្មជាតិ ជាពិសេសដីធ្លីកម្រិតទាប
- ការទទួលបានទីផ្សារនៅមានកម្រិតទាប
- ហានិភ័យខ្ពស់ពីជម្ងឺឆ្លង និងជម្ងឺផ្សេងៗ ព្រោះពួកគេជាអ្នកកាន់ផលិតផលសាច់សត្វស្រស់។

នៅពេលដែលស្ត្រីចូលរួមក្នុងកិច្ចការថែទាំសត្វចិញ្ចឹម បុរសជាអ្នកដែលជាទូទៅត្រូវបានអញ្ជើញអោយចូលរួមក្នុងវគ្គបណ្តុះបណ្តាល ពិភាក្សាជាមួយអ្នកផ្សព្វផ្សាយ ឬអ្នកសម្រេចចិត្ត។ល។ ក្នុងដំណើរការនេះ បុរសទទួលបានចំណេះដឹង និងជំនាញដែលពាក់ព័ន្ធទៅនឹងការចិញ្ចឹមបសុសត្វដែលជាទូទៅមិនត្រូវបានចែករំលែកជាមួយស្ត្រី ដែលជាលទ្ធផលធ្វើអោយការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាមានកម្រិតតិចតួច។ វត្តមានតិចតួចរបស់ស្ត្រីក្នុងស្ថាប័នសង្គម និងយន្តការចែករំលែកសេវាកម្មរបស់រដ្ឋាភិបាល និងភ្នាក់ងារក្រៅរដ្ឋាភិបាលធ្វើអោយការទទួលបានចំណេះដឹង និងសេវាកម្មរបស់ស្ត្រីជនបទមានភាពលំបាក។ ដោយសារតែមានកម្មសិទ្ធតិចតួច ឬគ្មានកម្មសិទ្ធដីក្នុងចំណោមស្ត្រី វាពិតជាមានការលំបាកសម្រាប់ពួកគេដើម្បីទទួលបានឥណទាន ដែលជះឥទ្ធិពលដល់ទំហំនៃការពង្រីកអាជីវកម្ម និងពង្រីកសកម្មភាពផ្សេងៗរបស់ពួកគេ។ វាទំនងជាថាស្ត្រីនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មានភាពផ្សេងគ្នាខ្លាំងលើសមត្ថភាពចរចាក្នុងទីផ្សារដោយពឹងផ្អែកលើទីកន្លែង ប្រពៃណីយ៍ និងវប្បធម៌។ ប៉ុន្តែ ក្នុងករណីទទួលបានទីផ្សារ ស្ត្រីជនបទជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនដោយសារតែកម្រិតចំណេះដឹង និងជំនាញទីផ្សាររបស់ពួកគេទាប

ក៏ដូចជាដែនកំណត់ក្នុងការចេញខាងក្រៅ(ការអនុវត្តប្រពៃណីយ៍ដែលការពារពួកគេចេញពីផ្ទះ ជំនាញបើកបរខ្សោយ)។ ទាំងនេះតម្រូវអោយធ្វើការដោះស្រាយដើម្បីលើកកម្ពស់ការទទួលបានរបស់ពួកគេក៏ដូចជាអំណាចចរចារក្នុងទីផ្សារ។

បុរសគ្រប់គ្រងលើចំណូល និងទ្រព្យសម្បត្តិដែលទទួលបានពីផលិតកម្មបសុសត្វច្រើនជាងស្ត្រី ដែលជាលទ្ធផលដល់ការកាត់បន្ថយឱកាសសម្រាប់ស្ត្រីក្នុងការទទួលបានឯករាជភាពសេដ្ឋកិច្ចក្នុងគ្រួសារ។ ពេលខ្លះចំណូលទទួលបានពីផលិតកម្មបសុសត្វត្រូវបានប្រើប្រាស់ខុសគោលដៅដោយបុរស និងមិនទទួលបានផលប្រយោជន៍ដល់គ្រួសារ។ មានភាពចាំបាច់ក្នុងការបង្កើនការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្ត មិនត្រឹមតែនៅក្នុងគ្រួសារប៉ុណ្ណោះទេ ថែមទាំងនៅក្នុងកម្រិតសហគមន៍ផងដែរ។ ការបង្កើនជម្រើសក្នុងការសម្រេចចិត្តនឹងលើកទឹកចិត្តអោយមានការបង្កើតបរិយាកាសកាន់តែទូលំទូលាយដល់ស្ត្រីដើម្បីទទួលបានជម្រើសស្មើរគ្នានឹងបុរស។ ដោយមានលេចចេញនូវប្រភេទជម្ងឺឆ្លងផ្សេងៗជាច្រើន ស្ត្រីមានហានិភ័យខ្ពស់ទៅនឹងជម្ងឺទាំងនេះ (ឧ. ជម្ងឺរលូតកូន ជម្ងឺរបេង)ដោយសារតែមានទំនាក់ទំនងផ្ទាល់ជាមួយសត្វចិញ្ចឹមដែលត្រូវបានគ្រប់គ្រងក្រោមបរិយាកាសស្អានសន្តិសុខជីវសាស្ត្រ និងការរៀបចំផលិតផល សត្វស្រស់ដែលមានកម្រិតទាប។

យោងតាមអង្គការ អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO)
មានបញ្ហាប្រឈមសំខាន់ៗ៧ប្រភេទដែលកសិករខ្នាតតូច និងជាពិសេសកសិករស្ត្រីប្រឈមៈ ការទទួលបាន
និងគ្រប់គ្រងលើធនធានធម្មជាតិ ការបែងចែកតួនាទី និងការទទួលខុសត្រូវផ្អែកលើភេទ និងអាយុ
ការទទួលបានបច្ចេកវិទ្យា សេវាកម្មបណ្តុះបណ្តាល និងផ្សព្វផ្សាយ ការទទួលបានសេវាកម្មហិរញ្ញវត្ថុ
ការទទួលបានទីផ្សារ ការចូលរួម និងអំណាចធ្វើការសម្រេចចិត្ត និងសុខភាព និងសុវត្ថិភាពការងារ
(អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ  2013)។

ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានក្នុង យុទ្ធសាស្ត្រវិស័យបសុសត្វ ៤ ឆ្នាំ
២០១៦-២០២០៖ ការគាំទ្រអ្នកចិញ្ចឹមសត្វខ្នាតតូចដើម្បីកាត់បន្ថយភាពក្រីក្រ ធ្វើអោយអាហាររូបត្ថម្ភបានប្រសើរ
សន្តិសុខស្បៀង និងសមភាព     យេនឌ័រ រួមបញ្ចូលសកម្មភាពខ្លះផ្តោតលើសមភាពយេនឌ័រ។
បញ្ហាយេនឌ័រខាងក្រោមគួរតែត្រូវបានពិចារណាយោងតាមប្រភេទនៃការប្រឈមទាំង៧របស់
អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ពេលបង្កើតគោលនយោបាយ ឬកម្មវិធីក្រោម
ផែនការយុទ្ធសាស្ត្រសកម្មភាព(SPA) សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានក្នុងវិស័យបសុសត្វឆ្នាំ ២០១៦-២០២០៖

- ពង្រឹងជំនាញបច្ចេកទេសរបស់ស្ត្រីតាមរយការសម្របសម្រួលរួមជាប្រព័ន្ធក្នុងការបណ្តុះបណ្តាលក្នុងការអនុ
  វត្តការចិញ្ចឹមបសុសត្វ ការកែច្នៃ និងការរកទីផ្សារផលិតផលបសុសត្វ
  ដែលជានាថាវគ្គបណ្តុះបណ្តាលទាំងនេះត្រូវបានផ្តល់អោយក្នុងភូមិ និងសហគមន៍តូចៗ។
- ផ្តល់អោយនូវឱកាសសម្រាប់ស្ត្រីទទួលបានសេវាហិរញ្ញវត្ថុផ្សេងៗគ្នា ដូចជាឥណទាន ការសន្សំ កម្ចី
  និងការធានារ៉ាប់រង ដើម្បីផ្តល់អោយពួកគេជាមួយឱកាសពង្រីកផលិតកម្មបសុសត្វរបស់ពួកគេ។
- លើកទឹកចិត្ត និង សម្របសម្រួលការទទួលបានរបស់ស្ត្រីទៅនឹងការអប់រំ
  ក៏ដូចជាការចូលរួមរបស់ពួកគេក្នុងវគ្គបណ្តុះបណ្តាលដោយមានគោលបំណងធ្វើអោយប្រសើរឡើងទីផ្សារ
  ពាណិជ្ជកម្ម និងជំនាញ     អាជីវកម្មរបស់ស្ត្រី។
- ផ្តល់អោយការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដើម្បីពង្រឹង និងពង្រីកសំលេង
  និងភាពជាអ្នកដឹកនាំក្នុងសហគមន៍ និងអង្គភាពអ្នកផលិតផ្សេងៗទៀត។

ទទួលស្គាល់ផ្នែកយេនឌ័រនៃហានិភ័យសុខុមាលភាព និងសុវត្ថិភាពការងារ ដូចជាការប៉ះពាល់ផ្ទាល់ទៅនឹងជម្ងឺឆ្លង
ដូចជាគ្រុនផ្តាសាយបក្សី (HPAI) និងគ្រោះថ្នាក់ផ្សេងៗទៀតទាក់ទងនឹងការកាន់សាច់ស្រស់
និងផលិតផលទឹកដោះគោ។

### 3.2.2 ដំណាំ

ក្រុមការងារតាមវិស័យលើផលិតកម្មដំណាំរបស់អាស៊ាន
(ASWGC)គឺជាស្ថាប័នមួយក្នុងចំណោមស្ថាប័នផ្សេងៗដែលស្ថិតនៅក្រោម
កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ពិសេសនៃរដ្ឋមន្ត្រីកសិកម្មនិងរុក្ខាប្រមាញ់អាស៊ាន (SOM-AMAF)
ដែលមានតួនាទីពិនិត្យមើលកិច្ចសហប្រតិបត្តិការអាស៊ានលើអនុវិស័យដំណាំ។
ដោយមានគោលដៅលើកកម្ពស់ការអភិវឌ្ឍន៍លើអនុវិស័យនេះ
ក្រុមការងារតាមវិស័យលើផលិតកម្មដំណាំរបស់អាស៊ាន (ASWGC) បានអនុវត្តសកម្មភាព
និងគម្រោងជាច្រើនយោងទៅតាម គោលបំណងយុទ្ធសាស្ត្ររបស់ខ្លួន
ដោយត្រូវបានឆ្លុះបញ្ចាំងក្នុងផែនការសកម្មភាពយុទ្ធសាស្ត្ររបស់ខ្លួន (SPA) លើដំណាំ។ សកម្មភាព
ឬគម្រោងមួយចំនួនបានអនុវត្តដោយជោគជ័យ និងមានច្រើនទៀតកំពុងបន្តអនុវត្ត តាមរយការរៀបចំបណ្តាញ
ក៏ដូចជាត្រូវបានគាំទ្រដោយកិច្ចសន្ទនា និងដៃគូអភិវឌ្ឍន៍ផ្សេងៗ។ ទំហំការងាររបស់
ក្រុមការងារតាមវិស័យលើផលិតកម្មដំណាំរបស់អាស៊ាន (ASWGC)  គ្រប់ដណ្តប់លើ៖ i) ក្របខ័ណ្ឌគោលនយោបាយ,
ii) ពាណិជ្ជកម្មលើផលិតផលដំណាំក្នុង និងក្រៅតំបន់អាស៊ាន, iii) ការគ្រប់គ្រងកត្តាចង្រៃ និងជម្ងឺរុក្ខជាតិ, iv)
ការអភិវឌ្ឍន៍ស្តង់ដារ និងការផ្សព្វផ្សាយរបស់ខ្លួន, v) កិច្ចការពារ      បរិស្ថានលើផលិតកម្មដំណាំ និង vi)
សន្តិសុខស្បៀង សុវត្ថិភាពចំណីអាហារ និងអាហាររូបត្ថម្ភ។

ការកើនឡើងនូវតួនាទីរបស់ស្ត្រីនៅក្នុងប្រព័ន្ធស្បៀង
និងដំណាំកំណត់ពួកគាត់ថាជាតួអង្គនិងជាដៃគូសំខាន់នៅក្នុងដំណើរការនេះ។ នៅអាស៊ានស្ត្រីមានចំនួនជាង
៥០នៃកម្លាំងពលកម្ម %ក្នុងវិស័យកសិកម្ម។
កសិករជាស្ត្រីនិងបុរសមានតួនាទីផ្សេងៗគ្នាទាក់ទងនឹងការផលិតកម្មដំណាំប៉ុន្តែនៅពីខាងក្រោយនៃការនៃការផ្លា
ស់ប្តូរឱកាសសេដ្ឋកិច្ចនិងលក្ខខណ្ឌបរិស្ថានការបែងចែកយេនឌ័រនៃកម្លាំងពលកម្មអាចនឹងផ្លាស់ប្តូរ។
កសិករជាស្ត្រីនិងបុរសតែងតែមានលក្ខណៈវិនិច្ឆ័យផ្សេងគ្នាក្នុងការជ្រើសរើសដំណាំនិងពូជនិងសកម្មភាពផ្សេងៗដូ
ចជាការជ្រើសរើសគ្រាប់ពូជការដាំដុះការប្រមូលផលនិងការកែច្នៃ។
លក្ខណៈវិនិច្ឆ័យទាំងនេះអាចផ្អែកលើភាពខុសគ្នានៃរសជាតិលក្ខណៈនៃការស្តុកទុក
ពេលវេលាដែលត្រូវការសម្រាប់ការរៀបចំអាហារតម្រូវការកម្លាំងពលកម្មនិងទីផ្សារ។
ជារឿយៗស្ត្រីក៏ខ្វះការធានាកាន់កាប់និងកម្មសិទ្ធិធនធាន
ការទទួលបានធនធានដូចជាដីហិរញ្ញវត្ថុព័ត៌មានសេវាកម្មផ្សព្វផ្សាយ និងបច្ចេកវិទ្យា។
ការបិទគម្លាតយេនឌ័រក្នុងការទទួលនិងការប្រើប្រាស់ធនធាននិងសេវាកម្មប្រកបដោយផលិតភាពនឹងបើកសក្តា
នុពលផលិតភាពកសិកម្មរបស់ស្ត្រីដោយបង្កើនទិន្នផលកសិកម្មយ៉ាងច្រើន។

ការសិក្សាអំពីគម្លាតទិន្នផលរវាងកសិករបុរស

និងស្ត្រីបានផ្តល់នូវការប៉ាន់ប្រមាណអំពីគម្លាតជាមធ្យមដែលមានចន្លោះពី ២០ ទៅ ៣០ ភាគរយ ហើយហេតុផលសំខាន់នៃគំលាតនេះគឺបណ្តាលមកពីការប្រើប្រាស់ធាតុចូលកសិកម្មក្នុងកម្រិតតិចដោយស្ត្រី។ យោងតាមការប៉ាន់ស្មានរបស់ អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ផលិតភាពកើនឡើងដែលជាលទ្ធផលពីការធានាឱ្យបាននូវលទ្ធភាពទទួលបានជីគ្រាប់ពូជនិងឧបករណ៍កសិកម្មស្មើគ្នាសម្រាប់ស្ត្រីអាចបង្កើនទិន្នផលកសិកម្មសរុបនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ប្រមាណ ២,៥ ទៅ ៤ ភាគរយដោយកាត់បន្ថយចំនួនអ្នកអត់ឃ្លានចន្លោះពី ១០០ ទៅ ១៥០ លាននាក់បើយោងតាមទិន្នន័យដែលទទួលបានដោយ FAO ក្នុងឆ្នាំ ២០១១។

បញ្ហាយេនឌ័រខាងក្រោមគួរតែត្រូវបានពិចារណាពេលអនុវត្តគម្រោង ឬសកម្មភាពក្រោមផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានលើដំណាំ ២០១៦-២០២០៖

- ធ្វើការវិភាគយេនឌ័រនៅក្នុងគ្រប់គម្រោងកម្មវិធីនិងគោលនយោបាយទាំងអស់ដើម្បីវាយតម្លៃលើការសន្និដ្ឋាននិងអត្ថប្រយោជន៍នៃបច្ចេកវិទ្យានិងការអនុវត្តកសិកម្មឆ្លាតវៃអាកាសធាតុ (CSA) លើបុរសនិងស្ត្រី ។
- ផ្តល់ការគាំទ្រជាក់លាក់ដល់ស្ត្រីដែលដឹកនាំសហគ្រាសខ្នាតតូចនិងមធ្យម និងសហគមន៍ដើម្បីបង្កើនផលិតភាពបច្ចេកវិទ្យានិងគុណភាពផលិតផលដើម្បីបំពេញតាមស្តង់ដារទីផ្សារពិភពលោកនិងបង្កើនការប្រកួតប្រជែង។
- ផ្តល់ការបណ្តុះបណ្តាលដល់ស្ត្រីនិងបុរសអំពីបច្ចេកវិទ្យានិងការអនុវត្ត កសិកម្មឆ្លាតវៃអាកាសធាតុ (CSA) និងការយល់ដឹងអំពីយេនឌ័រ។
- សម្របសម្រួលការទទួលបានដីនិងឥណទានរបស់ស្ត្រីតាមរយៈការផ្លាស់ប្តូរច្បាប់និងការអនុវត្តមូលដ្ឋានពង្រឹងសមត្ថភាពសមាជិកស្ត្រីនិងបុរសរបស់អង្គការនិងស្ថាប័នកសិករស្ត្រីនិងបុរសដើម្បីចូលរួមជាមួយវិស័យឯកជន។

## 3.2.3 វិស័យជលផល និងវារីវប្បកម្ម

វិស័យជលផលដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស/រដ្ឋជាសមាជិកអាស៊ាន។ប្រទេសនៅអាស៊ានចំនួន ៦ រួមមានឥណ្ឌូនេស៊ុីមីយ៉ាន់ម៉ាហ្វីលីពីនវៀតណាមថៃនិងម៉ាឡេស៊ីស្ថិតក្នុងចំណោមប្រទេសដែលផលិតត្រីធំជាងគេនៅលើពិភពលោកខណៈប្រទេសចំនួន ៤ គឺឥណ្ឌូនេស៊ីហ្វីលីពីនម៉ាឡេស៊ីនិងវៀតណាមស្ថិតក្នុងចំណោមប្រទេសផលិតសារ៉ាយសមុទ្រលំដាប់ពិភពលោក។ប្រជាជនប្រមាណ ៦០ លាននាក់ធ្វើការក្នុងវិស័យជលផលទាក់ទងនឹងសេវាកម្មគាំទ្រចាំបាច់ ដូចជាផលិតទូក ផលិតឧបករណ៍នេសាទ ការកែច្នៃត្រីនិងទីផ្សារ។ នៅក្នុងតំបន់អាស៊ាន ការទទួលទានត្រីសម្រាប់មនុស្សម្នាក់ដែលមានចំនួន៣៣,៤គីឡូក្រាមក្នុងមួយឆ្នាំ

គឺម៉ានកម្រិតខ្ពស់ជាងគេខ្លាំងបើប្រៀបធៀបជាមួយមធ្យមភាគនៃការទទួលទានត្រីពិភពលោកដែលមានចំនួន ១៩,២ គីឡូក្រាមក្នុងមួយឆ្នាំ។ ហើយប្រហែល ៣៨ភាគរយនៃប្រូតេអ៊ីនសត្វគឺទទួលបានមកពីសត្វត្រីដែលសបញ្ជាក់អំពីសារៈសំខាន់នៃវិស័យ ជលផលនិងសន្តិសុខស្បៀងអាហារក្នុងតំបន់។

ក្រុមការងារតំបន់អាស៊ានស្តីពីជលផល(ASWGFi)មានភារកិច្ចត្រួតពិនិត្យការកំណត់អត្តសញ្ញាណ ការបង្កើតការត្រួតពិនិត្យ និងការរាយការណ៍អំពីកិច្ចសហប្រតិបត្តិការជលផល ក្នុងចំណោមសមាជិកអាស៊ាន។

ដោយទទួលស្គាល់បញ្ហាយេនឌ័រទាំងនេះគោលការណ៍ណែនាំស្តីពីជលផលខ្នាតតូចប្រកបដោយនិរន្តរភាពរួមមានសមភាពយេនឌ័រនិងគោលការណ៍សមភាពមួយក្នុងចំណោមគោលការណ៍ណែនាំទាំង ១៣ របស់វាហើយយេនឌ័រក៏ត្រូវបានពិចារណានៅក្នុងផ្នែកលម្អិតបន្ថែមទៀតស្តីពីជលផលប្រកបដោយការទទួលខុសត្រូវនិងការអភិវឌ្ឍន៍ប្រកបដោយចីរភាព (អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ ២០១៥ ) គោលការណ៍ណែនាំ ជលផលខ្នាតតូចប្រកបដោយនិរន្តរភាព (SSF) ទទួលស្គាល់ថាពលកម្មក្នុងវិស័យជលផលរបស់ស្ត្រីនិងបុរសតែងតែត្រូវបានផ្តល់នូវតម្លៃវប្បធម៌និងសេដ្ឋកិច្ចខុសៗគ្នាដោយការងាររបស់ស្ត្រីតែងតែមានរាប់មិនអស់ហើយមិនត្រូវបានគិតនៅក្នុងអភិបាលកិច្ចជលផលទេទោះបីជាមានសារៈសំខាន់ចំពោះជលផលខ្នាតតូចក៏ដោយ។ វាក៏ទទួលស្គាល់ផងដែរនូវចំនុចស្នូលនៃយេនឌ័រចំពោះបញ្ហាប្រសព្វផ្សេងទៀតជាពិសេសសិទ្ធិមនុស្សនិងសុខុមាលភាពសន្តិសុខស្បៀងនិងការប្រែប្រួលអាកាសធាតុហើយវាក៏បង្ហាញពីភាពខុសគ្នារវាងយេនឌ័រនៅក្នុងអំណាចនិងការសម្រេចចិត្តកើតមាននៅក្នុងបរិបទជលផលខ្នាតតូចនិងភាពខុសគ្នាទាំងនោះមានឥទ្ធិពលតំណាង យុត្តិធម៌ និងអភិបាលកិច្ចជលផលខ្នាតតូចប្រកបដោយនិរន្តរភាព។ អន្តរាគមន៍ដែលកំណត់តួនាទីរបស់ស្ត្រីនៅក្នុងប្រព័ន្ធជលផលនិងវារីវប្បកម្មដោយផ្អែកលើតួនាទីបន្តពូជនិងតួនាទីសេដ្ឋកិច្ចដែលមានស្រាប់របស់ពួកគេពិតជាអាចរក្សាបាននូវស្ថានភាពដែលអាចមានវិសមភាពខ្ពស់ចំពោះស្ត្រីជនបទនិងជនជាតិដើមភាគតិច។

បញ្ហាយេនឌ័រខាងក្រោមគួរតែពិចារណាពេលអនុវត្តគម្រោង ឬសកម្មភាពក្រោមផែនការសកម្មភាពយុទ្ធសាស្ត្រ SPA សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានលើវិស័យជលផល ២០១៦-២០២០៖

- ផ្តល់អំណាចដល់ស្ត្រីក្នុងការគ្រប់គ្រងជលផលតាមសហគមន៍តាមរយៈការកសាងសមត្ថភាពលើបញ្ហាបច្ចេកទេសនិងច្បាប់ផ្សេងៗ។
- ផ្តល់ឱ្យអ្នកនេសាទនូវលទ្ធភាពទទួលបានធនធាននេសាទទីផ្សារហិរញ្ញវត្ថុនិងធនធានទីផ្សារ
- លើកទឹកចិត្តឱ្យមានការតស៊ូមតិអំពីប្រាក់ឈ្នួលស្មើគ្នាចំពោះកម្លាំងជលផល។
- លើកទឹកចិត្តពង្រឹងសមត្ថភាពសហជីពនិងស្ថាបនស្ត្រីតាមរយៈយន្តការបែងចែកធនធាននិងបង្កើនការទទួលខុសត្រូវផ្នែកគ្រប់គ្រងរបស់ពួកគេ។
- លើកទឹកចិត្តស្ត្រីឱ្យចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងវារីវប្បកម្មដែលមិននៅលើដីផ្សេងៗ និងស្ទឹងដូចជាការផលិតកម្មពូជនិងការប្រមូលផល និងកែច្នៃចំណីនិងផលិតផលសត្វទឹក។
- តាមដានការផ្លាស់ប្តូរការគ្រប់គ្រងធនធានដើម្បីវាយតម្លៃវិសាលភាពដែលក្របខ័ណ្ឌផ្លូវការនិងក្រៅផ្លូវការដែលមានស្រាប់អាចឱ្យទីភ្នាក់ងារសម្លេងនិងឱកាសរបស់ស្ត្រីក្នុងវិស័យជលផលកំណត់អាទិភាពសម្រាប់ការផ្លាស់ប្តូរ។
- ធានាឱ្យមានការគាំទ្រដល់ការស្រាវជ្រាវអំពីយេនឌ័រក្នុងវិស័យជលផល។

### 3.2.4 ព្រៃឈើ

ព្រៃឈើដើរតួយ៉ាងសំខាន់ក្នុងការផលិតកម្មឈើនិងផលិតផលផ្សេងៗទៀតនិងផ្តល់ជំរកដល់ប្រជាជនខ្វះខាតនៅអនុតំបន់ហើយផ្តល់ការងារនៅក្នុងនោះរួមមានការផលិតគ្រឿងសង្ហារឹមនិងផលិតផលឈើផ្សេងទៀតការគ្រប់គ្រងតំបន់ការពារនិងការអភិវឌ្ឍន៍ចម្ការ។ព្រៃឈើមានសារៈសំខាន់សម្រាប់ប្រជាជនក្នុងតំបន់ជនជាតិដើមភាគតិចនិងជនបទព្រោះពួកវាផ្តល់អាហារថាមពលនិងជម្រកដល់ប្រជាជនរាប់លាននាក់នៅក្នុងតំបន់អាស៊ាន។

មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីព្រៃឈើ (ASOF) គឺជាស្ថាប័នទទួលខុសត្រូវចំពោះកិច្ចសហប្រតិបត្តិការ
ព្រៃឈើនៅអាស៊ាន។ មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីព្រៃឈើ (ASOF)
បានបង្កើតចក្ខុវិស័យនៃកិច្ចសហប្រតិបត្តិការដែល“ធនធានព្រៃឈើត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាពនៅកម្រិតទេសភាពដើម្បីបំពេញតម្រូវការសង្គម ទាំងសេដ្ឋកិច្ចសង្គម និងវប្បធម៌របស់មនុស្សជំនាន់បច្ចុប្បន្ននិងអនាគតនិងដើម្បីរួមចំណែកជាវិជ្ជមានដល់
ការអភិវឌ្ឍន៍ប្រកបដោយចីរភាព”។គោលដៅសម្រាប់វិស័យព្រៃឈើនៅអាស៊ានគឺ“ពង្រឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពសម្រាប់ការបន្តផលិតកម្ម ទំនិញ
និងសេវាកម្មព្រៃឈើប្រកបដោយតុល្យភាពនិងធានាការការពារព្រៃឈើនិងការអភិរក្សជីវៈចម្រុះព្រមទាំងបង្កើនប្រសិទ្ធភាពការប្រើប្រាស់សមស្របនឹងសង្គមនិងអេកូឡូស៊ីប្រកបនិរន្តរភាព។

នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ប្រជាជនចំនួន ៣០០ លាននាក់រស់នៅក្នុងតំបន់ជនបទហើយប្រជាជនរហូតដល់ ៧០ លាននាក់ពឹងផ្អែកលើព្រៃឈើសម្រាប់ជីវភាពរស់នៅអាហារូបត្ថម្ភនិងសន្តិសុខស្បៀងរបស់ពួកគេ។
បុរសនិងស្ត្រីតែងតែប្រើប្រាស់និងពឹងផ្អែកខុសគ្នាលើអនុផលព្រៃឈើដោយស្ត្រីតែងតែពឹងផ្អែកលើផលិតផលទាំងនេះយ៉ាងខ្លាំង។
ស្ត្រីចូលរួមចំណែកក្នុងវិស័យព្រៃឈើតាមវិធីជាច្រើនទាំងផ្លូវការនិងក្រៅផ្លូវការរួមទាំងតាមរយៈការធ្វើកសិ-រុក្ខកម្មការគ្រប់គ្រងតំបន់ផ្ទៃទឹក ការកែលម្អដើមឈើនិងការការពារព្រៃឈើ។
ស្ត្រីមានសមាមាត្រកម្លាំងពលកម្មច្រើននៅក្នុងឧស្សាហកម្មព្រៃឈើទូទាំងពិភពលោកជាពិសេសនៅក្នុងការងារបណ្តុះកូនឈើប៉ុន្តែក៏មានសកម្មភាពផ្សេងៗទៀតផងដែរចាប់ពីការកាប់ឈើរហូតដល់ការកែច្នៃឈើ។
ទោះបីជាស្ត្រីបានរួមចំណែកយ៉ាងច្រើនដល់វិស័យព្រៃឈើក៏ដោយតួនាទីរបស់ពួកគេមិនត្រូវបានគេទទួលស្គាល់ឬកត់ត្រាបានពេញលេញឡើយហើយប្រាក់ឈ្នួលនិងលក្ខខណ្ឌការងាររបស់ពួកគេគឺទាបជាងបុរស។
ជាងនេះទៅទៀតស្ត្រីកម្រមានការចូលរួមស្មើគ្នាជាមួយបុរសក្នុងការបង្កើតផែនការនិងការអនុវត្តគោលនយោបាយព្រៃឈើ។ មានផលប៉ះពាល់យេនឌ័រនៃការបំផ្លាញព្រៃឈើផងដែរ៖
ចំពោះបុរសការកាប់បំផ្លាញព្រៃឈើអាចនាំឱ្យបាត់បង់ប្រាក់ចំណូលចំណែកឯស្ត្រីវិញអាចបង្កើនបន្ទុកការងារកម្លាំងពលកម្មរបស់ពួកគេជាពិសេសនៅពេលប្រមូលអុស។

ការកំណត់ផ្នែកសេដ្ឋកិច្ចសង្គមវប្បធម៌នយោបាយនិងច្បាប់អាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិស្ត្រីនិងបុរសក្នុងការគ្រប់គ្រងធនធានព្រៃឈើនិងដីផ្ទាល់ខ្លួន។សូម្បីតែកន្លែងខ្លះដែលស្ត្រីមានសិទ្ធិជាម្ចាស់លើព្រៃឈើក៏ដោយក៏ពួកគេមិនអាចមានភាពស្មើគ្នាសម្រាប់ឱកាសបង្កើតចំណូលពីព្រៃឈើដែរ។ជាទូទៅស្ត្រីអាចមានលទ្ធភាពទទួលបានអនុផលព្រៃឈើ
ប៉ុន្តែមិនមែនជាធនធានឈើដែលជាកម្មសិទ្ធិរបស់បុរសនិងជាផលិតផលដែលមានតំលៃខាងពាណិជ្ជកម្មនៅក្នុងព្រៃភាគច្រើន។ភាពខុសគ្នានៃយេនឌ័រនេះមានផលប៉ះពាល់ធំធេងចំពោះការគ្រប់គ្រងព្រៃឈើនិងរចនាសម្ព័ន្ធអំណាចផ្អែកលើយេនឌ័រនៅក្នុងសហគមន៍។ការសិក្សាស្រាវជ្រាវមួយធ្វើឡើងដោយធនាគារពិភពលោកបានរកឃើញថាការផ្តល់ឱ្យស្ត្រីនូវការបញ្ចេញយោបល់ច្រើនជាងមុនក្នុងការគ្រប់គ្រងព្រៃឈើធ្វើអោយប្រសើរឡើងនូវលទ្ធផលអភិរក្ស ២០១២ ធនាគារពិភពលោកឆ្នាំ)) ។

អ្នកពាក់ព័ន្ធសំខាន់មួយទៀតគឺសហគមន៍ជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់ព្រៃឈើដែលពឹងផ្អែកលើ

ព្រៃឈើដើម្បីការរស់រានមានជីវិតរបស់ពួកគេ។ធនាគារពិភពលោកប៉ាន់ប្រមាណថាមានជនជាតិដើមភាគតិចដែលពឹងផ្អែកលើព្រៃឈើប្រមាណ ៦០ លាននាក់ដែលអ្នកស្រាវជ្រាវជឿថាត្រូវបានមើលរំលង) Tauli-Corpuz, ២០១១ ។ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) ទទួលស្គាល់យ៉ាងពេញលេញអំពីសារៈសំខាន់នៃដី

ដែនដីនិងធនធានសម្រាប់ជនជាតិដើមភាគតិច។នេះត្រូវបានសង្កត់ធ្ងន់បន្ថែមទៀតតាមរយការទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិចដើម្បីទទួលបានការព្រមព្រៀងជាមុនដោយសេរីនិងមានព័ត៌មាន (FPIC) ជាតម្រូវការដើម្បីការពារសិទ្ធិរបស់យើងលើដីដែនដីនិងធនធាននិងសិទ្ធិក្នុងការប្តេជ្ញាចិត្តរបស់យើង។ស្ត្រីជនជាតិដើមភាគតិចងាយរងគ្រោះបំផុតចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងសារៈសំខាន់នៃចំណេះដឹងគុណតម្លៃនិងការអនុវត្តប្រពៃណីរបស់ពួកគេនិងតម្រូវការដើម្បីរួមគ្នាកសាងនូវអ្វីដែលនៅសេសសល់ដើម្បីលើកស្ទួយភាពធន់របស់សហគមន៍ទាំងសម្រាប់ជំនាន់បច្ចុប្បន្ននិងអនាគត។

បញ្ហាយេនឌ័រខាងក្រោមគួរតែពិចារណាពេលអនុវត្តគម្រោង ឬសកម្មភាពក្រោមផែនការសកម្មភាពយុទ្ធសាស្ត្រ SPA សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានលើការងារព្រៃឈើ ២០១៦-២០២០៖

1. លើកទឹកចិត្តសមាជិកអាស៊ានដើម្បីបង្ហាញពីគោលនយោបាយព្រៃឈើដែលឆ្លើយតបទៅនឹងយេនឌ័រក្នុងការកាន់កាប់សិទ្ធិទទួលបានតំណាងនៅក្នុងឱកាសកសាងសមត្ថភាព។
2. ចាប់ផ្តើមកិច្ចសន្ទនា និងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីពិភាក្សាបញ្ហា និងគម្លាតយេនឌ័រក្នុងគោលនយោបាយ និងការអនុវត្តដែលមានស្រាប់។
3. បញ្ចូលអង្គការសង្គមស៊ីវិល ស្ថាបនសហគមន៍ស្ថាប័នរដ្ឋាភិបាលនិងបណ្តាញស្ត្រីពាក់ព័ន្ធដើម្បីធានាបាននូវវិធីសាស្ត្ររួមក្នុងការអភិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយព្រៃឈើឆ្លើយតបនឹងយេនឌ័រ
4. រៀបចំសិក្ខាសាលាស្តីពីការយល់ដឹងអំពីយេនឌ័រសម្រាប់មន្ត្រីព្រៃឈើរួមទាំងអ្នកធ្វើសេចក្តីសម្រេចចិត្តនិងសមាជិកគណៈកម្មាធិការគោលនយោបាយដើម្បីធានាការយល់ដឹងកាន់តែស៊ីជម្រៅអំពីភាពពាក់ព័ន្ធនៃកង្វល់របស់ស្ត្រីចំពោះគោលនយោបាយនិងកម្មវិធីព្រៃឈើ
5. ពង្រឹងសមត្ថភាពស្ថាប័នដែលធ្វើការងារយេនឌ័រនិងជនបង្គោលយេនឌ័រនៅក្នុងស្ថាប័នដើម្បីចូលរួមក្នុងកម្រិតដ៏សំខាន់មួយនៅក្នុងការពិគ្រោះយោបល់ទាក់ទងនឹងព្រៃឈើនិងក្នុងការពិនិត្យគោលនយោបាយនិងដំណើរការអភិវឌ្ឍន៍
6. លើកទឹកចិត្តដល់ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធក្នុងរចនាសម្ព័ន្ធគ្រប់គ្រងដែលមានស្រាប់ដើម្បីកំណត់អតុល្យភាពអំណាចយេនឌ័រនិងជួយសម្រួលដល់ការបង្កើតស្ថាប័នព្រៃឈើដែលមានតុល្យភាពយេនឌ័របន្ថែមទៀត។នេះមានសារៈសំខាន់ណាស់ក្នុងការបង្កើនតំណាងស្ត្រីក្នុងតួនាទីដឹកនាំនិងការចូលរួមរបស់ពួកគេក្នុងការសម្រេចចិត្ត
7. វិភាគនិន្នាការការងាររវាងបុរសនិងស្ត្រីជាពិសេសភាគរយនៃស្ត្រីដែលទទួលបានការអប់រំទាក់ទងនឹងព្រៃឈើព្រមទាំងការជ្រើសរើសនិងអត្រានៃការរក្សាស្ត្រីនៅក្នុងវិស័យព្រៃឈើ។
8. ធានាឱ្យមានការចែករំលែកផលប្រយោជន៍ប្រកបដោយសមធម៌ រវាងស្ត្រីនិងបុរសនៅកន្លែងដែលពាក់ព័ន្ធ។ (ឧទាហរណ៍ការទូទាត់ថ្លៃសេវាកម្មបរិស្ថាន)
9. ផ្តល់សិទ្ធិអំណាចដល់ស្ត្រីតាមរយៈការកសាងសមត្ថភាពរបស់ពួកគេដើម្បីចូលរួមក្នុងគម្រោងស្តារស្តារដីព្រៃ/ឡើងវិញ។
10. តាមដានគោលនយោបាយព្រៃឈើតាមរយៈការឆ្លុះបញ្ចាំងយេនឌ័រនៅក្នុងក្របខ័ណ្ឌអភិបាលកិច្ចព្រៃឈើដែលកំពុងរីកចម្រើន

### 3.2.5 ការប្រែប្រួលអាកាសធាតុ

តំបន់អាស៊ីអាគ្នេយ៍មានភាពងាយរងគ្រោះខ្ពស់ទៅនឹងការប្រែប្រួលអាកាសធាតុដោយសារតែអត្រាប្រជាជននិងសកម្មភាពសេដ្ឋកិច្ចត្រូវបានប្រមូលផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រ។តំបន់នេះពឹងផ្អែកយ៉ាងខ្លាំងលើវិស័យកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ការពឹងផ្អែកខ្ពស់លើធនធានធម្មជាតិនិងព្រៃឈើ និងកំរិតនៃភាពក្រីក្រនៅតែខ្ពស់។ស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ងាយរងគ្រោះជាពិសេសទៅនឹងការប្រែប្រួលអាកាសធាតុពីព្រោះពួកគេពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានធម្មជាតិក្នុងតំបន់សម្រាប់ការរស់នៅរបស់ពួកគេ។ស្ត្រីទទួលបន្ទុកក្នុងការធានានិរន្តរភាពទឹកសម្រាប់ប្រើប្រាស់ ម្ហូបអាហារនិងប្រេងឥន្ធនៈសម្រាប់ចម្អិនអាហារនិងកំដៅដែលប្រឈមនឹងបញ្ហាធំបំផុត។ស្ត្រីជួបប្រទះនូវភាពមិនស្មើគ្នាក្នុងលទ្ធភាពទទួលបានធនធាននិងដំណើរការនៃការសម្រេចចិត្តជាមួយនឹងការកំណត់ការប្រមូលផ្តុំនៅតំបន់ជនបទ។ដូច្នេះ វាមានសារៈសំខាន់ដើម្បីកំណត់យុទ្ធសាស្ត្រយេនឌ័រដែលឆ្លើយតបទៅនឹងវិបត្តិទាំងនេះចំពោះស្ត្រី។

ស្ត្រីនិងបុរសមានលទ្ធភាពប្រើប្រាស់ធនធានផ្សេងៗគ្នា ដីឥណទាន

បច្ចេកវិទ្យាកសិកម្ម ដើម្បីដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកន្លែងដែលស្ត្រីមានធនធានតិចតួចជាងបុរស។ បញ្ហានេះបង្កើនភាពងាយរងគ្រោះ និងកំណត់សមត្ថភាពរបស់ពួកគេដើម្បីសម្របទៅនឹងការផ្លាស់ប្តូរអាកាសធាតុ។ វិធានការសម្រប និងកាត់បន្ថយការប្រែប្រួលអាកាសធាតុឧទាហរណ៍ យន្តការការពារសង្គមគម្រោងធានារ៉ាប់រងផ្អែកលើអាកាសធាតុការព្យាករណ៍អាកាសធាតុតាមរដូវនិងវិធានការទាក់ទងនឹងព្រៃឈើ ឬការផ្ទុកកាបូនដីជារឿយៗមិនបានដោះស្រាយបញ្ហាយេនឌ័រ និងជាពិសេសឧបសគ្គរបស់ស្ត្រីក្នុងការចូលរួមក្នុងវិធានការទាំងនេះ។ជាទូទៅស្ត្រីប្រឈមនឹងហានិភ័យខ្ពស់ក្នុងការឆ្លើយតបទៅនឹងគ្រោះថ្នាក់ធម្មជាតិនិងបន្ទុកកាន់តែច្រើនពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ទោះបីជាពួកគេមានចំនេះដឹងក្នុងតំបន់ស្រាប់ និងជាអ្នកគ្រប់គ្រងធនធានធម្មជាតិទូទៅក៏ដោយតែពួកគេច្រើនតែនៅឆ្ងាយពីរូបភាពនៅពេលមានការសម្រេចចិត្តលើសកម្មភាពអាកាសធាតុ។

ប្រទេសរដ្ឋជាសមាជិកនៅក្នុងសន្និសីទប្រចាំឆ្នាំរបស់ភាគី COP23

ដែលប្រជុំពីថ្ងៃទី ៦ ដល់ថ្ងៃទី ១៧ ខែវិច្ឆិកាឆ្នាំ ២០១៧ នៅទីក្រុងប៊ន ប្រទេសអាល្លឺម៉ង់បានអនុម័តផែនទីបង្ហាញផ្លូវថ្មីមួយដើម្បីបញ្ចូលសមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រីក្នុងសុន្ទរកថានិងសកម្មភាពផ្លាស់ប្តូរអាកាសធាតុ។ ការបង្កើត “ផែនការសកម្មភាពយេនឌ័រ” ត្រូវបានគ្រប់ភាគីឯកភាពគ្នានៅCOP22 ដើម្បីពង្រឹងតួនាទីរបស់ស្ត្រីនៅក្នុងសកម្មភាពអាកាសធាតុ។ គោលបំណងនៃផែនការសកម្មភាពយេនឌ័រគឺដើម្បីធានាថាស្ត្រីអាចជះឥទ្ធិពលទៅដល់ការសម្រេចចិត្តនៃការប្រែប្រួលអាកាសធាតុហើយស្ត្រីនិងបុរសត្រូវបានតំណាងស្មើភាពគ្នានៅគ្រប់ទិដ្ឋភាពទាំងអស់នៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) ដែលជាមធ្យោបាយបង្កើនប្រសិទ្ធភាពរបស់វា។ផែនការសកម្មភាពយេនឌ័រកំណត់ក្នុងវិស័យអាទិភាពចំនួន ៥ សកម្មភាពដែលនឹងជួយសម្រេចគោលបំណងនេះ។

- បង្កើនចំណេះដឹងនិងសមត្ថភាពស្ត្រីនិងបុរសតាមរយៈសិក្ខាសាលានិងការផ្លាស់ប្តូរព័ត៌មាន
- បង្កើនការចូលរួមដោយស្មើភាពគ្នានិងមានអត្ថន័យរបស់ស្ត្រីក្នុងប្រតិភូថ្នាក់ជាតិ
- បង្កើនសមាហរណកម្មនៃការពិចារណាយេនឌ័រដូចជាការដោះស្រាយភាពងាយរងគ្រោះជាក់លាក់របស់ស្ត្រីចំពោះគ្រោះធម្មជាតិក៏ដូចជាការយល់ដឹងពីតួនាទីរបស់ស្ត្រីក្នុងវិស័យកសិកម្មនិងការផលិតស្បៀងអាហារនិងការគាំទ្រសហគ្រិនស្ត្រីនៅក្នុងវិស័យថាមពលក្នុងវិស័យការងាររបស់គ្រប់ភាគីនៃអនុសញ្ញា-
- បង្កើនធនធានហិរញ្ញវត្ថុទាក់ទងនឹងអាកាសធាតុដែលរួមបញ្ចូលអាទិភាពយេនឌ័រនិងឆ្លុះបញ្ចាំងពីតម្រូវការរបស់ស្ត្រីនិងក្មេងស្រី។
- ធ្វើឱ្យប្រសើរឡើងនូវការតាមដានការអនុវត្តការសម្រេចចិត្តទាក់ទងនឹងយេនឌ័រ។

ក្រុមការងារអាស៊ានលើការប្រែប្រួលអាកាសធាតុ )AWGCC) ត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យការអនុវត្តបន្ទាត់សកម្មភាពពាក់ព័ន្ធនៅក្នុងផែនការមេក្នុងសហគមន៍វប្បធម៌និងសង្គមអាស៊ាន)ASCC)។គោលបំណងមួយនៃផែនការមេសហគមន៍វប្បធម៌និងសង្គមអាស៊ាន (ASCC 2025)គឺការសំរេចបាននូវសហគមន៍ដែលមានភាពរឹងមាំជាមួយនឹងការពង្រឹងសមត្ថភាពនិងលទ្ធភាពក្នុងការសម្របខ្លួននិងឆ្លើយតបទៅនឹងភាពងាយរងគ្រោះផ្អែកសង្គមនិងសេដ្ឋកិច្ចគ្រោះមហន្តរាយការប្រែប្រួលអាកាសធាតុព្រមទាំងការគំរាមកំហែងនិងបញ្ហាប្រឈមថ្មីៗ។

បញ្ហាយេនឌ័រខាងក្រោមនេះគួរតែត្រូវបានពិចារណានៅពេលអនុវត្តផែនការមេសហគមន៍វប្បធម៌និងសង្គមអាស៊ាន (ASCC 2025)។

- ធ្វើការវិភាគស៊ីជម្រៅនិងផ្អែកលើភស្តុតាងអំពីតួនាទីរបស់ស្ត្រីនិងបុរសនៅក្នុងវិស័យដែលរងផលប៉ះពាល់និងយុទ្ធសាស្ត្ររបស់ពួកគេក្នុងការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។
- បញ្ចូលទស្សនៈយេនឌ័រនៅគ្រប់កម្មវិធីប្រែប្រួលអាកាសធាតុដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទាំងតម្រូវការនិងអាទិភាពរបស់ស្ត្រីនិងបុរសធានាឱ្យមានការចូលរួមពេញលេញនិងមានអត្ថន័យរបស់ស្ត្រីនិងសម្រេចបាននូវសមភាពយេនឌ័រ។
- ធានាកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយនិងសម្របសម្រួលដើម្បីដោះស្រាយប្រភពនៃភាពងាយរងគ្រោះផ្អែកលើយេនឌ័រវិសមភាពយេនឌ័រនិងភាពក្រីក្រ។

បញ្ចូលទស្សនៈយេនឌ័រទៅក្នុងយន្តការនិងយុទ្ធសាស្ត្រហិរញ្ញវត្ថុនៃការប្រែប្រួលអាកាសធាតុជាតិនិងអន្តរជាតិ

## 3.2.6 សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

អាស៊ានបានស្វែងរកការធានាសន្តិសុខស្បៀងសម្រាប់តំបន់បង្កើនផលិតភាពកសិកម្មនិងរក្សានិរន្តរភាពនៃធនធានធម្មជាតិ។ដោយទទួលស្គាល់ពីការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងទីផ្សារពិភពលោកនិងផលប៉ះពាល់របស់វាទៅលើវិស័យកសិកម្មនិងព្រៃឈើព្រមទាំងការផ្លាស់ប្តូររចនាសម្ព័ន្ធនៅក្នុងវិស័យទាំងនេះដែលជាលទ្ធផលនៃការធ្វើឧស្សាហូបនីយកម្មផែនការសកម្មភាពហាណូយ )HPA) និងកម្មវិធីសកម្មភាពវៀងចន្ទន៍បន្ត )VAP) ស្តីពីវិស័យស្បៀងអាហារកសិកម្មនិងព្រៃឈើបានអំពាវនាវឱ្យ“លើកកម្ពស់សន្តិសុខស្បៀងនិងការប្រកួតប្រជែងជាសកលនៃផលិតផលម្ហូបអាហារកសិកម្មនិងព្រៃឈើរបស់អាស៊ានតាមរយៈការអភិវឌ្ឍន៍បច្ចេកវិទ្យាសមស្របដើម្បីបង្កើនផលិតភាពនិងការលើកកម្ពស់ពាណិជ្ជកម្មក្នុង និងក្រៅតំបន់អាស៊ាន និងការវិនិយោគវិស័យឯកជនលើវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ”។

អសន្តិសុខស្បៀងអាហារនិងអាហារូបត្ថម្ភគឺជាបញ្ហាយុត្តិធម៌យេនឌ័រ។ឋានៈទាបនិងកង្វះលទ្ធភាពទទួលបានធនធានមានន័យថាស្ត្រីនិងកុមារីជួបការលំបាកបំផុតដោយសារដំណើរការសេដ្ឋកិច្ចពិភពលោកមិនស្មើភាពដែលគ្រប់គ្រងប្រព័ន្ធស្បៀងអាហារនិងនិន្នាការពិភពលោកដូចជាការប្រែប្រួលអាកាសធាតុ។ភស្តុតាងបង្ហាញពីការជាប់ទាក់ទងយ៉ាងខ្លាំងរវាងវិសមភាពយេនឌ័រនិងអសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។ទំនាក់ទំនងយេនឌ័ររវាងនិងក្នុងចំណោមបុរសនិងស្ត្រីមានសារៈសំខាន់ក្នុងការកំណត់ភាពងាយរងគ្រោះចំពោះអសន្តិសុខស្បៀងនិងកង្វះអាហារូបត្ថម្ភ។ការរើសអើងយេនឌ័រក្នុងការបែងចែកធនធានគ្រួសាររួមទាំងផ្នែកដែលទាក់ទងនឹងអាហារូបត្ថម្ភអាចបណ្តាលឱ្យមានការកើនឡើងនូវអត្រាកង្វះអាហារូបត្ថម្ភក្នុងចំណោមស្ត្រីនិងក្មេងស្រី។ នេះអាចត្រូវបានកើតឡើងក្នុងពេលមានវិបត្តិ។ភាពងាយរងគ្រោះកាន់តែខ្លាំងចំពោះអសន្តិសុខស្បៀងក្នុងពេលមានវិបត្តិបង្កបញ្ហានៃអសន្តិសុខស្បៀង។

ការវិភាគដោយវិទ្យាស្ថានសិក្សាអភិវឌ្ឍន៍) IDS ២០១៤ ( ស្តីពីយេនឌ័រនិងសន្តិសុខស្បៀងបានសង្កត់ធ◌្ងន់ថាតម្រូវការសម្រាប់អ្នកដែលរៀបចំគោលនយោបាយនិងកម្មវិធីសន្តិសុខស្បៀងអាហារនិងអាហារូបត្ថម្ភដើម្បីផ្តោតលើសសរស្តម្ភទីមួយនៃការធានាឱ្យមានស្បៀងអាហារនៅក្នុងប្រទេសក្រីក្រតាមរយៈយុទ្ធសាស្ត្ររយៈពេលខ្លីនៃជំនួយស្បៀងអាហារនិងយុទ្ធសាស្ត្ររយៈពេលវែងផ្តោតលើការជំរុញផលិតកម្មកសិកម្មដែលពឹងផ្អែកលើគំរូឧស្សាហកម្មនិងការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម។សសរស្តម្ភទាំងបួននៃសន្តិសុខស្បៀង-ភាពអាចរកបាន លទ្ធភាពទទួលបានការប្រើប្រាស់ និងស្ថិរភាពដែលត្រូវបានកំណត់នៅក្នុងកិច្ចប្រជុំកំពូលពិភពលោកស្តីពីសន្តិសុខស្បៀងក្នុងឆ្នាំ ២០០៩ផ្តល់នូវធាតុចូលដែលមានប្រយោជន៍សម្រាប់ការវិភាគកាន់តែទូលំទូលាយអំពីបញ្ហាអសន្តិសុខស្បៀងអាហារនិងការដោះស្រាយបញ្ហាបច្ចុប្បន្នមិនគ្រប់គ្រាន់, និងការឆ្លើយតបគោលនយោបាយ។

បញ្ហាយេនឌ័រខាងក្រោមគួរតែពិចារណាពេលអនុវត្តគម្រោង ឬសកម្មភាពក្រោមផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានលើសន្តិសុខស្បៀង ២០១៦-២០២០៖

- បង្កើនភាពស៊ីសង្វាក់គ្នារវាងគោលនយោបាយលើយេនឌ័រកសិកម្មអាហារូបត្ថម្ភសុខភាពពាណិជ្ជកម្មនិងវិស័យពាក់ព័ន្ធផ្សេងទៀតតាមរយៈដំណើរការថ្នាក់ជាតិនិងតំបន់។
- ទទួលស្គាល់និងគោរពចំនេះដឹងមូលដ្ឋានរបស់កសិកររួមទាំងស្ត្រីជាកសិករសម្រាប់ការអភិវឌ្ឍន៍ដំណោះស្រាយសន្តិសុខសុវត្ថិភាពស្បៀងនិងអាហារូបត្ថម្ភដែលពាក់ព័ន្ធក្នុងស្រុក។
- បង្កើតវិធីសាស្ត្រត្រឹមត្រូវខាងអេកូឡូស៊ីចំពោះការផលិតម្ហូបអាហារដូចជាកសិ-អេកូឡូស៊ីដែលលើកម្ពស់ការធ្វើកសិកម្មប្រកបដោយនិរន្តរភាពនិងការផ្តល់អំណាចដល់ស្ត្រី។
- លើកកម្ពស់ការអនុវត្តសិទ្ធិរបស់ប្រជាជនទាំងអស់ចំពោះអាហារនិងជាពិសេសសិទ្ធិស្ត្រីចំពោះធនធានផ្សេងទៀតដូចជាដីនៅថ្នាក់មូលដ្ឋាននិង
- បញ្ចូលសមាជិកស្ត្រីនិងបុរសនៃសហគមន៍កសិករនិងសហគ្រាសធុនតូចនិងមធ្យមក្នុងការប្រកួតប្រជែងការចែកចាយអាហារមិនស្មើភាពគ្នា។

## 3.2.7 ការបញ្ចូលយេនឌ័រទៅក្នុងខ្សែច្រវ៉ាក់ផលិតកម្មចំណីអាហារ កសិកម្ម និងព្រៃឈើ

ការបិទ“គម្លាតយេនឌ័រ”ក្នុងវិស័យកសិកម្មអាចបណ្ដាលឱ្យមានការកើនឡើងផលិតកម្មខ្លាំង៖ របាយការណ៍របស់អង្គការFAO ស្ដីពីស្ថានភាពស្បៀងអាហារនិងកសិកម្មឆ្នាំ ២០១០ ២០១១- បានកំណត់ថាទិន្នផលរបស់ស្ត្រីអាចកើនឡើង ២០៣-០ ភាគរយប្រសិនបើគម្លាតយេនឌ័រក្នុងការទទួលបានធាតុចូលកសិកម្មត្រូវបានបិទការកើនឡើងដែលអាចបង្កើនទិន្នផលកសិកម្មសរុបនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ពី ២,៥ ទៅ ៤ ភាគរយដែលអាចកាត់បន្ថយចំនួនប្រជាជនមិនមានសុវត្ថិភាពស្បៀងអាហារនៅលើពិភពលោកពី ១២ ទៅ ១៧ ភាគរយ )FAO ឆ្នាំ

២០១១។នៅក្នុង(បរិបទនេះការរួមបញ្ចូលការពិចារណាយេនឌ័រទៅក្នុងការអភិវឌ្ឍន៍ខ្សែច្រវ៉ាក់តម្លៃកសិកម្មមិនត្រឹមតែចាំបាច់ពីទស្សនៈសិទ្ធិមនុស្សប៉ុណ្ណោះទេ។វាក៏ជាលក្ខខណ្ឌតម្រូវជាមុនដើម្បីធានាដល់កំណើនប្រកបដោយចីរភាពនៅក្នុងផ្នែកអន្តរាគមន៍។

កម្មវិធីខ្សែច្រវ៉ាក់តម្លៃដែលត្រូវបានបង្កើតឡើងដោយមានគោលការណ៍សមភាពយេនឌ័រអាចរួមបញ្ចូលទាំងការប្រកួតប្រជែងនិងសមភាពយេនឌ័រនិងនាំទៅដល់ការកាត់បន្ថយភាពក្រីក្រ។វាមានសារៈសំខាន់ណាស់ក្នុងការធ្វើផែនទីទំនាក់ទំនងយេនឌ័រនិងតួនាទីតាមខ្សែច្រវ៉ាក់តម្លៃ។ដំណើរការនេះផ្អែកលើការយល់ដឹងត្រឹមត្រូវអំពីទំនាក់ទំនងយេនឌ័រដែលមានស្រាប់នៅក្នុងបរិបទប្រទេសណាជាក់លាក់មួយនិងសម្រាប់ផលិតផលម្ហូបអាហារកសិកម្មនិងព្រៃឈើជាក់លាក់។វាគួរតែរួមបញ្ចូលការគូសផែនទីការចូលរួមនិងអត្ថប្រយោជន៍របស់បុរសនិងស្ត្រីនៅតាមខ្សែច្រវ៉ាក់និងកំណត់កត្តាដែលកំណត់លំនាំយេនឌ័រនៅក្នុងប្រតិបត្តិការខ្សែច្រវ៉ាក់តម្លៃ។សក្តានុពលយេនឌ័រត្រូវបានចងភ្ជាប់ដោយវដ្តនៃការអភិវឌ្ឍន៍តម្លៃ៖ ប្រសិទ្ធភាពខ្សែច្រវ៉ាក់តម្លៃគឺពឹងផ្អែកយ៉ាងខ្លាំងទៅលើការភ្ជាប់ទំនាក់ទំនងយ៉ាងរឹងមាំនិងកិច្ចសហការវិជ្ជមានក្នុងចំណោមតួអង្គហើយស្ត្រីគឺជាអ្នកពាក់ព័ន្ធសំខាន់នៅតាមខ្សែវ៉ាក់តម្លៃទោះបីជាពួកគេមើលមិនឃើញឬមើលរំលងក៏ដោយ។

ក្របខ័ណ្ឌខ្សែច្រវ៉ាក់តម្លៃយេនឌ័ររបស់(GSVC)ផ្តោតលើកម្រិតបុគ្គលនិងពិនិត្យទៅលើឧបសគ្គដែលផ្អែកលើយេនឌ័រដែលជាមូលហេតុមូលដ្ឋាននៃភាពគ្មានប្រសិទ្ធភាពនៃខ្សែច្រវ៉ាក់តម្លៃ។គោលបំណងរបស់ GSVC គឺដើម្បីកំណត់បញ្ហាប្រឈមយេនឌ័រនៅគ្រប់ដំណាក់នៃខ្សែច្រវ៉ាក់តម្លៃដូចជាការចូលរួមក្នុងខ្សែច្រវ៉ាក់ ការទទួលនិងការត្រួតពិនិត្យលើធនធានដែលមានផលិតភាពនិងការទទួលបាននិងការត្រួតពិនិត្យលើអត្ថប្រយោជន៍)FAO ២០១៦( ។

បញ្ហាយេនឌ័រខាងក្រោមគួរតែពិចារណាពេលបញ្ចូលបញ្ហាយេនឌ័រក្នុងខ្សែច្រវ៉ាក់តម្លៃកសិកម្ម៖

- ធ្វើការស្រាវជ្រាវដើម្បីស្វែងយល់ពីតួនាទីនិងការទទួលខុសត្រូវរបស់បុរសនិងស្ត្រីនៅក្នុងខ្សែច្រវ៉ាក់តម្លៃកសិកម្ម
- ដោះស្រាយតម្រូវការកសាងសមត្ថភាពរបស់ស្ត្រីនៅក្នុងខ្សែច្រវ៉ាក់តម្លៃកសិកម្ម
- គាំទ្រការអភិវឌ្ឍន៍សេដ្ឋកិច្ចស្ត្រី
- លើកកម្ពស់ដំណោះស្រាយទីផ្សារដែលផ្អែកលើសមភាពយេនឌ័រ
- បង្កើតយន្តការចែករំលែកផលប្រយោជន៍ប្រកបដោយសមធម៌
- រួមបញ្ចូលស្ត្រីក្នុងការកំណត់បញ្ហានិងដំណោះស្រាយ
- ផ្តល់ឱកាសដល់ស្ត្រីក្នុងការទទួលបាននូវការចូលនិងព័ត៌មានទីផ្សារ
- ជួយក្រុមស្ត្រីក្នុងការទិញឧបករណ៍ដើម្បីពង្រីកដំណើរការ
- ជួយស្ត្រីឱ្យយកឈ្នះឧបសគ្គនៃការចល័តនិងឧបសគ្គសង្គម
- លើកទឹកចិត្តឱ្យសហគ្រាសដែលគ្រប់គ្រងដោយស្ត្រីកាន់តែច្រើនចូលរួមសមាគមពាណិជ្ជកម្ម
- ដោះស្រាយបរិយាកាសការងារកន្លែងធ្វើការដែលមានសុវត្ថិភាពសម្រាប់សុខុមាលភាពស្ត្រី/

# 4. យុទ្ធសាស្ត្រថ្នាក់តំបន់ និងផែនការសកម្មភាព

## 4.1 ការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ

មានទស្សនវិស័យយេនឌ័រសំខាន់ៗនៅក្នុងគ្រប់ផ្នែកទាំងអស់ក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ។ វិសមភាពយេនឌ័រក្នុងការទទួលបានធនធានរួមមានដីឥណទានសេវាកម្មផ្សព្វផ្សាយព័ត៌មាននិងបច្ចេកវិទ្យាត្រូវតែយកមកពិចារណាក្នុងការអភិវឌ្ឍន៍គោលនយោបាយកម្មវិធីនិងសកម្មភាពម្ហូបអាហារ កសិកម្មនិងព្រៃឈើ។ ស្ត្រីជាអ្នកក្រីក្រមួយចំនួនធំនៅក្នុងសហគមន៍ដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានធម្មជាតិក្នុងតំបន់សម្រាប់ការរស់នៅរបស់ពួកគេនិងងាយរងគ្រោះនិងរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ។ ស្ត្រីនៅតំបន់ជនបទក្នុងប្រទេសកំពុងអភិវឌ្ឍន៍មានទំនួលខុសត្រូវចម្បងចំពោះការផ្គត់ផ្គង់ទឹកក្នុងគ្រួសារនិងថាមពលសម្រាប់ចម្អិនអាហារនិងកំដៅក៏ដូចជាសន្តិសុខស្បៀងនិងរងផលប៉ះពាល់អវិជ្ជមានដោយសារគ្រោះរាំងស្ងួតរបបទឹកភ្លៀងមិនច្បាស់លាស់និងការកាប់បំផ្លាញព្រៃឈើ។ ដោយសារតែតួនាទីរបស់ពួកគេលទ្ធភាពទទួលបានធនធានមិនស្មើគ្នានិងការចល័តមានកំណត់ស្ត្រីនៅក្នុងបរិបទជាច្រើនត្រូវរងផលប៉ះពាល់ដោយគ្រោះធម្មជាតិដូចជាទឹកជំនន់ភ្លើងឆេះនិង បាក់ដី។ វាមានសារៈសំខាន់ណាស់ក្នុងការកំណត់យុទ្ធសាស្ត្រដែលប្រកាន់យកយេនឌ័រសម្រាប់ឆ្លើយតបទៅនឹងវិបត្តិបរិស្ថាននិងមនុស្សធម៌ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

ប្រទេសសមាជិកអាស៊ានគួរតែត្រូវបានលើកទឹកចិត្តក្នុងការបញ្ជ្រាបទស្សនៈយេនឌ័រទៅក្នុងគោលនយោបាយជាតិផែនការសកម្មភាពនិងវិធានការផ្សេងទៀតស្តីពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនិងការប្រែប្រួលអាកាសធាតុតាមរយៈការអនុវត្តការវិភាគយេនឌ័រជាប្រព័ន្ធការប្រមូលនិងការប្រើប្រាស់ទិន្នន័យដែលមិនបែងចែកភេទបង្កើតសូចនាករ និងគោលកំណត់ដែលប្រកាន់យកយេនឌ័រនិងការបង្កើតឧបករណ៍ជាក់ស្តែងដើម្បីគាំទ្រការយកចិត្តទុកដាក់បន្ថែមចំពោះទស្សនៈយេនឌ័រ។ការពិគ្រោះយោបល់និងការចូលរួមរបស់ស្ត្រីក្នុងការផ្តួចផ្តើមការប្រែប្រួលអាកាសធាតុគួរតែត្រូវបានពិចារណាហើយតួនាទីរបស់ក្រុមស្ត្រីនិងបណ្តាញត្រូវបានពង្រឹង។

## 4.2ក្របខ័ណ្ឌសម្រាប់យុទ្ធសាស្ត្រសម្រាប់បញ្ជ្រាបយេនឌ័រក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ

វិធីសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើកំណត់គោលដៅយុទ្ធសាស្ត្ររួមដូចជា៖“ដើម្បីសម្របសម្រួលនិងលើកកម្ពស់គោលនយោបាយរចនាសម្ព័ន្ធនិងកម្មវិធីកសិកម្មដែលមានភាពធន់ដើម្បីលើកកម្ពស់សមភាពយេនឌ័រឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅឆ្នាំ ២០២៥” ។

### 4.2.1 វិធីសាស្ត្រ និងការគាំទ្រ

គោលបំណងគឺដើម្បីលើកកម្ពស់និងគាំទ្រឱ្យមានសមភាពយេនឌ័រនៅក្នុងគោលនយោបាយកម្មវិធីប្រព័ន្ធនិងរចនាសម្ព័ន្ធស្បៀងអាហារកសិកម្មនិងព្រៃឈើនៅថ្នាក់តំបន់និងថ្នាក់ជាតិ។សកម្មភាពខាងក្រោមអាចត្រូវបានពិចារណា៖

- បង្កើនកិច្ចសហការនិងចែករំលែកព័ត៌មានពាក់ព័ន្ធជាមួយស្ថាប័នតំបន់និងថ្នាក់ជាតិអង្គការនិងដៃគូអភិវឌ្ឍន៍ដែលធ្វើការក្នុងវិស័យយេនឌ័រ។
- តស៊ូមតិអំពីសមភាពយេនឌ័រនៅក្នុងគោលនយោបាយស្បៀងអាហារកសិកម្មនិងព្រៃឈើជាមួយនឹងការគ្រប់គ្រងកម្រិតកំពូលនៅក្នុងក្រុមការងារវិស័យពាក់ព័ន្ធរបស់អាស៊ាន។
- លើកកម្ពស់ការចែករំលែកបទពិសោធន៍និងមេរៀនដែលទទួលបានតាមរយៈការផ្តល់ឱកាសដល់ស្ត្រីឱ្យចូលរួមក្នុងវេទិកាថ្នាក់តំបន់និងអន្តរជាតិពាក់ព័ន្ធនឹងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ។
- ធានាឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីអ្នកជំនាញយេនឌ័រនិងស្ថាបនស្ត្រីក្នុងដំណើរការពិគ្រោះយោបល់សម្រាប់ការបង្កើតយុទ្ធសាស្ត្របន្សាំនិងកាត់បន្ថយនិងគោលនយោបាយស្បៀងកសិកម្មនិងព្រៃឈើ។
- លើកកម្ពស់កសិកម្មអភិរក្សនិងកសិកម្មឆ្លាតវៃឆ្លើយតបទៅនឹងអាកាសធាតុនិងសកម្មភាពពាក់ព័ន្ធកសិកម្មប្រកប)ដោយនិរន្តរភាព ( ដែលរួមបញ្ចូលកសិករខ្នាតតូចប្រុសនិងស្រីដែលត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាវិសមភាពយេនឌ័រ។

- លើកកម្ពស់ការផលិតកម្មសំភារៈនិងការបោះពុម្ពផ្សាយក្នុងគោលបំណងដោះស្រាយនិន្នាការយេនឌ័រនិងភាពអយុត្តិធម៌វប្បធម៌ក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ។
- លើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ។
- កំណត់គោលនយោបាយដែលមានស្រាប់ស្តីពីយេនឌ័រនៅថ្នាក់តំបន់និងថ្នាក់ជាតិ

## 4.2.2 ការកសាងសមត្ថភាព

គោលបំណងគឺដើម្បីពង្រឹងនិងកសាងសមត្ថភាពអ្នកធ្វើគោលនយោបាយកម្មករនិងកសិករអំពីវិធីសាស្ត្រសមស្របក្នុងការធ្វើសមាហរណកម្មយេនឌ័រក្នុងវិស័យកសិកម្មនិងការប្រែប្រួលអាកាសធាតុ។សកម្មភាពខាងក្រោមអាចត្រូវបានពិចារណាៈ

- ធ្វើការវាយតម្លៃដើម្បីកំណត់ពីតម្រូវការសមត្ថភាពរបស់អ្នកពាក់ព័ន្ធទាំងអស់។
- គាំទ្រប្រទេស ឬរដ្ឋជាសមាជិកដើម្បីបង្កើតម៉ូឌុលបណ្តុះបណ្តាលស្តីពីកសិកម្មឆ្លាតវៃនិងយេនឌ័រ។
- គាំទ្រប្រទេស ឬរដ្ឋជាសមាជិកដើម្បីអភិវឌ្ឍន៍សមត្ថភាពសម្រាប់យន្តការវាយតម្លៃផលប៉ះពាល់យេនឌ័រ។
- ជំរុញការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មជាស្ត្រី។
- សម្របសម្រួលការអភិវឌ្ឍន៍មូលដ្ឋានទិន្នន័យយេនឌ័រដើម្បីបញ្ចូលចំណេះដឹងនិងបទពិសោធន៍របស់ស្ត្រីក្នុងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាពនិងជាពិសេសលើប្រព័ន្ធផលិតកម្មកសិកម្ម។
- សម្របសម្រួលការកសាងសមត្ថភាពរបស់ក្រុមគ្រូបង្គោល/ជនបង្គោលលើវិស័យកសិកម្មឆ្លាតវៃឆ្លើយតបទៅនឹងអាកាសធាតុ និងយេនឌ័រ។

## 4.2.3 ក្របខ័ណ្ឌស្ថាបន

គោលបំណងគឺដើម្បីពង្រឹងទំនាក់ទំនងរវាងស្ថាបនថ្នាក់តំបន់និងស្ថាប័នជាតិដែលទទួលខុសត្រូវចំពោះយេនឌ័រកសិកម្មនិងការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់និងថ្នាក់ជាតិសកម្មភាពខាងក្រោមអាចត្រូវបានពិចារណាៈ

- បង្កើតការវិភាគស្ថានភាពនៃស្ថាប័នថ្នាក់តំបន់និងថ្នាក់ជាតិដែលបានជ្រើសរើសដើម្បីកំណត់សមត្ថភាពរបស់ពួកគេក្នុងការបញ្ចូលទស្សនវិស័យយេនឌ័រទៅក្នុងគំនិតផ្តួចផ្តើមកសិកម្មនិងការប្រែប្រួលអាកាសធាតុ។
- លើកកម្ពស់ការផ្លាស់ប្តូរការអនុវត្តល្អបំផុតរបស់ស្ថាប័ននិងអង្គការដែលគាំទ្រដល់ភាពជាអ្នកដឹកនាំកសិករស្ត្រីនៅក្នុងសហគមន៍ និងសមាគមន៍កសិករ។
- ពង្រឹងដល់កើនឡើងនៃការចូលរួមរបស់ក្បាលម៉ាស៊ីន និងបញ្ជាបយេនឌ័រថ្នាក់ក្នុងការអភិវឌ្ឍន៍ក្របខ័ណ្ឌកសិកម្មនិងការវិនិយោគជាតិ។
- ពង្រឹងរចនាសម្ព័ន្ធអង្គការចាប់ពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន ការធ្វើអោយមានសុខដុមនីយកម្មនិងការធ្វើមូលដ្ឋានីយកម្មនិងការពង្រឹងយន្តការត្រួតពិនិត្យនិងវាយតម្លៃ។

## 4.2.4 ការកសាង និងពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រ

គោលបំណងគឺបង្កើតនិងពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រនិងទំនាក់ទំនងត្រីភាគីនៅកម្រិតអន្តរជាតិនិងតំបន់រួមមានភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈ។សកម្មភាពខាងក្រោមអាចត្រូវបានពិចារណាៈ

- រៀបចំដំណើរទស្សនកិច្ចសិក្សាដើម្បីស្វែងយល់និងចែករំលែកបទពិសោធន៍ស្តីពីគំនិតផ្តួចផ្តើមយេនឌ័រកសិកម្មនិងការប្រែប្រួលអាកាសធាតុ។
- ផ្តល់វេទិកាដើម្បីកំណត់អត្តសញ្ញាណនិងបញ្ចូលប្រភពជំនួយសំខាន់ៗទៅដល់សកម្មភាពបញ្ជ្រាបយេនឌ័រ។

### 4.2.5 ព័ត៌មាន ការទំនាក់ទំនង និងការផ្សព្វផ្សាយ

គោលបំណងគឺបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានផ្តោតលើយេនឌ័រកសិកម្មនិងការប្រែប្រួលអាកាសធាតុសកម្មភាពខាងក្រោមអាចត្រូវបានពិចារណា៖

- បង្កើនការយល់ដឹងនិងទទួលបានព័ត៌មានកសិកម្មនិងការប្រែប្រួលអាកាសធាតុឱ្យបានគ្រប់គ្រាន់ជាពិសេសផ្តោតលើស្ត្រីយុវជននិងបុរស។
- បង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានផ្អែកទៅលើចំណេះដឹងដោយផ្តោតទៅលើយេនឌ័រកសិកម្មនិងការប្រែប្រួលអាកាសធាតុ។
- បង្កើតនិងផ្សព្វផ្សាយព័ត៌មាននិងសម្ភារៈចាំបាច់ទាក់ទងនឹងយេនឌ័រស្តីពីកសិកម្មនិងការប្រែប្រួលអាកាសធាតុ។

### 4.2.6 ការស្រាវជ្រាវ នវានុវត្ត និងបច្ចេកវិទ្យា

គោលបំណងគឺដើម្បីលើកកម្ពស់ការស្រាវជ្រាវសមភាពយេនឌ័រដែលគាំទ្រដល់បច្ចេកវិទ្យាកសិកម្មឆ្លាតវៃ។សកម្មភាពខាងក្រោមអាចត្រូវបានពិចារណា៖

- ធ្វើការវាយតម្លៃបឋមអំពីយេនឌ័រការអនុវត្តកសិកម្មអភិរក្សនិងបច្ចេកវិទ្យានៅក្នុងប្រទេសជាសមាជិក ។
- ពង្រឹងការស្រាវជ្រាវដើម្បីទទួលបានទិន្នន័យដ៏ទូលំទូលាយបន្ថែមទៀតអំពីទិដ្ឋភាពយេនឌ័ររបស់វិស័យកសិកម្មនិងការប្រែប្រួលអាកាសធាតុដើម្បីគាំទ្រដល់កសិកម្មឆ្លាតវៃ។

បង្កើនការស្រាវជ្រាវនិងការអភិវឌ្ឍន៍តាមបែបសហការណ៍ និងចូលរួមរួមទាំងការធ្វើឱ្យប្រសើរឡើងនូវបច្ចេកវិទ្យាព័ត៌មាននិងប្រព័ន្ធចំណេះដឹងដែលពាក់ព័ន្ធនិងសមស្របដើម្បីធានាថាបញ្ហាសមភាពយេនឌ័រត្រូវបានដោះស្រាយ។

## 5. ដំណើរអនុវត្ត

អនុសាសន៍នៅក្នុងវិធីសាស្ត្ររបស់ កិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់ (AMAF) ត្រូវបានប្រើជាឯកសារយោងសម្រាប់សមាជិកអាស៊ានក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យម្ហូបអាហារកសិកម្មនិងព្រៃឈើ។ SOM-AMAF ដោយមានការគាំទ្រពីការស្រាវជ្រាវនិងអភិវឌ្ឍន៍វិស័យកសិកម្ម(ATWGARD) ក្រុមការងារតំបន់អាស៊ានស្តីពីបសុសត្វ (ASWGL) ក្រុមការងារតាមវិស័យលើផលិតកម្មដំណាំរបស់អាស៊ាន (ASWGC) ក្រុមការងារតំបន់អាស៊ានស្តីពីជលផល (ASWGFi) មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីព្រៃឈើ (ASOF) និងក្រុមការងារពាក់ព័ន្ធផ្សេងទៀតអាចត្រូវបានណែនាំកន្លែងដែលពាក់ព័ន្ធតាមអនុសាសន៍នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានលើវិស័យកសិកម្មនិងរុក្ខាប្រមាញ់(AMAF) ។ ដោយមានការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋានអាស៊ាន ការស្រាវជ្រាវនិងអភិវឌ្ឍន៍វិស័យកសិកម្ម (ATWGARD) ប្រហែលជាត្រូវការស្វែងរកការគាំទ្រពីដៃគូអាស៊ាននិងភាគីពាក់ព័ន្ធផ្សេងៗក្នុងការអនុវត្តវិធីសាស្ត្ររបស់ AMAF ជាឯកសារយោង។

# ឯកសារយោង

*ASEAN, 2017: Declaration on the Gender-Responsive Implementation of the ASEAN Community Vision 2025 and Sustainable Development Goals*

*ASEAN, 2016: Projected Gender Impacted of the ASEAN Economic Community*

*ASEAN, 2015: Vision and Strategic Plan for ASEAN Cooperation in Food, Agriculture and Forestry, 2016-2025*

*ASEAN, 2010: Ha Noi Declaration on the Enhancement of Welfare and Development of ASEAN Women and Children*

*Black, R. E., L. H. Allen, Z. A. Bhutta, L. E. Caulfield, M. de Onis, M. Ezzati, C. Mathers, J. Rivera, 2008 for the Maternal and Child Undernutrition Study Group: Maternal and Child Undernutrition: Global and Regional Exposures and Health Consequences. The Lancet 371(9608):243–260*

*FAO. 2016. Developing gender-sensitive value chains – A guiding framework. Rome*

*FAO, 2013: CEDAW- Convention on the elimination of all forms of discrimination against women. A tool for gender – sensitive agriculture and rural development policy and programme formulation*

*FAO (2013) Understanding and integrating gender issues into livestock projects and programmes: A checklist for practitioners.*

*FAO, 2012: How to mainstream gender in forestry*

*FAO, 2008 The World Bank and IFAD: Gender in Agriculture, Sourcebook*

*FAO, 2008: World Fish Center and World Bank: Small-scale capture fisheries – A global overview with emphasis on developing countries: a preliminary report of the Big Numbers Project. FAO and Worl dFish Center, Rome & Penang, 62 pages*

*Porter, M. (2006) Gender and fisheries: A global perspective. Paper presented at Global Coasts: Gender, Fisheries and Contemporary Issues, International Symposium, University of Tromso, Norway, June 2006*

*UN, 2010: UN Joint programmes integrating gender issues in food security, agriculture and rural development*

*Tauli-Corpuz, Victoria. 2011. Indigenous women, climate change and forests. Baguio City, Philippines: Tebtebba Foundation.*

*World Bank, World Development Report 2012: Gender Equality and Development, Washington, DC, 2012*

*World Bank, Food and Agriculture Organization & International Fund for Agricultural Development, 2009. Gender in agriculture source book*

.

## ឧបសម្ព័ន្ធទី ១៖ អន្តរាគមន៍យេនឌ័រដែលត្រូវបានផ្តល់អនុសាសន៍នៅក្នុងផ្នែក SPAs

## SPAsខាងក្រោមត្រូវបានពិនិត្យដើម្បីបង្កើតអនុសាសន៍សម្រាប់វិធីសាស្ត្រ

## ផែនការយុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានលើវិស័យម្ហូបអាហារ កសិកម្ម និងព្រៃឈើ

## (២០១៦-២០២៥)

| ការជំរុញយុទ្ធសាស្ត្រ | ពណ៌នា | សកម្មភាព | កិច្ចអន្តរាគមន៍យេនឌ័រ |
|---|---|---|---|
| ST1 | បង្កើនបរិមាណនិងគុណភាពនៃការផលិតប្រកបដោយនិរន្តរភាពបច្ចេកវិទ្យា"បៃតង"ប្រព័ន្ធគ្រប់គ្រងធនធាននិងកាត់បន្ថយការបាត់បង់និងកាកសំណល់មុននិងក្រោយប្រមូលផល | 1.13.ធ្វើឱ្យស្តង់ដារនិងសុខដុមនីយកម្មគំនិតវិធីសាស្ត្រនិងការបង្ហាញស្ថិតិជាតិនិងពង្រឹងសមត្ថភាពបច្ចេកទេសរបស់AMSដើម្បីធ្វើការសិក្សាស្រាវជ្រាវពហុប្រទេសនិងធ្វើការវិភាគនិងរៀបចំផែនការស្ថានភាពបានត្រឹមត្រូវ។ | បង្កើតគំនិតនិងវិធីសាស្ត្រដែលមានការចុះសម្រុងគ្នាលើការធ្វើសមាហរណកម្មយេនឌ័រនៅក្នុងវិស័យស្បៀងអាហារកសិកម្មនិងព្រៃឈើ |
| ST2 | បង្កើនការសម្របសម្រួលពាណិជ្ជកម្មសមាហរណកម្មសេដ្ឋកិច្ចនិងការចូលទីផ្សារ | 2.5.បង្កើតទំនាក់ទំនងអាជីវកម្មក្នុងចំណោមសហគមន៍កសិកម្មដែលមានសក្តានុពលនិងអង្គការកសិករ។ | ធានាការចូលរួមរបស់សហគមន៍និងអង្គការស្ត្រី |
| ST3 | ធានាសន្តិសុខស្បៀងអាហារសុវត្ថិភាពអាហារូបត្ថម្ភល្អប្រសើរនិងការចែកចាយប្រកបដោយសមធម៌ | 3.5ធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងនិងអាហារូបត្ថម្ភតាមរយៈការធ្វើពិពិធកម្មប្រភពអាហារនិងការពង្រឹងគុណភាពនិងភាពខុសគ្នានៃការផលិតម្ហូបអាហារនិងការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់តម្លៃអាហារ។ | ការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តនិងការអនុវត្តសកម្មភាពនេះមានសារៈសំខាន់ណាស់។ |
| ST4 | បង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុគ្រោះធម្មជាតិនិងផលប៉ះពាល់ផ្សេងៗ។ | 4.7ធ្វើសមាហរណកម្មបញ្ហាយេនឌ័រទៅក្នុងវិស័យកសិកម្មភេតរះអាកាសធាតុការនេសាទនិងព្រៃឈើដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រីចំពោះផលប៉ះពាល់សង្គមនិងសេដ្ឋកិច្ចនៃគ្រោះធម្មជាតិនិងការប្រែប្រួលអាកាសធាតុ។ | កសាងសមត្ថភាពដើម្បីបញ្ជូលយេនឌ័រ |

| | | | |
|---|---|---|---|
| ST5 | ជួយអ្នកផលិតខ្នាតតូចដែលមានបញ្ហាប្រឈមធនធាន និងសហគ្រាសខ្នាតតូចនិងមធ្យមដើម្បីកែលម្អផលិតភាពបច្ចេកវិទ្យានិងគុណភាពផលិតផលដើម្បីបំពេញតាមស្តង់ដារទីផ្សារពិភពលោកនិងបង្កើនការប្រកួតប្រជែងស្របតាមផែនការគោលនយោបាយអាស៊ានស្តីពីការអភិវឌ្ឍន៍ សហគ្រាសធុនតូចនិងមធ្យម។ | 5.5អនុវត្តគោលនយោបាយប្រកួតប្រជែងដើម្បីធានាឱ្យមានការប្រកួតប្រជែងកម្រិតសម្រាប់អ្នកផលិតនិងសហគ្រាសធុនតូចនិងមធ្យម និងដើម្បីការពារការកេងប្រវ័ញ្ចអយុត្តិធម៌ដោយក្រុមហ៊ុនធំ ៗ ដែលមានអំណាចទីផ្សារក្នុងខ្សែសង្វាក់ផ្គត់ផ្គង់រួមបញ្ចូលគ្នា។ | ខណៈកំពុងពិចារណាលើកម្រិតដើរតួនាទីមូលដ្ឋាន ក៏ត្រូវគិតគូរពីបញ្ហាសមធម៌យេនឌ័រផងដែរ។ |
| ST6 | ពង្រឹងវិធីសាស្ត្ររួមគ្នារបស់អាស៊ានលើបញ្ហាអន្តរជាតិនិងតំបន់ | 6.2បង្ហាញជំហររួមរបស់អាស៊ានលើបញ្ហាដែលជះឥទ្ធិពលដល់វិស័យFAF ក្នុងតំបន់និងពិភពលោក | បង្ហាញជំហររួមអាស៊ានស្តីពីសមភាពយេនឌ័រក្នុងបញ្ហាស្បៀងអាហារកសិកម្មនិងព្រៃឈើដែលជះឥទ្ធិពលដល់វិស័យ FAF ក្នុងវេទិកាតំបន់និងពិភពលោក |
| ST7 | លើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព | 7.3ផ្សព្វផ្សាយការពិភាក្សាជាមួយវិស័យឯកជនអំពីការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃឧស្សាហកម្មឈើនិងការកែច្នៃផលិតផលព្រៃឈើផ្សេងទៀត | លើកកម្ពស់ការពិភាក្សាថ្នាក់តំបន់ស្តីពីបញ្ហាយេនឌ័រក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព |

## ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA)
## សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍វិស័យកសិកម្ម

## ២០១៦-២០២០

| ការជំរុញយុទ្ធសាស្ត្រ | ពណ៌នា | សកម្មភាព | កិច្ចអន្តរាគមន៍យេនឌ័រ |
|---|---|---|---|
| ST1 | លើកកម្ពស់បរិមាណនិង. គុណភាពនៃការផលិតដោយបច្ចេកវិទ្យាប្រកបដោយនិរន្តរភាពប្រព័ន្ធគ្រប់គ្រងធនធាននិងកាត់បន្ថយការខាតបង់មុននិងក្រោយប្រមូលផល | 1.2បង្កើនការចូលរួមរបស់វិស័យឯកជនក្នុងការពិភាក្សាគោលនយោបាយកម្មវិធីនិងការបង្កើតគម្រោងការស្រាវជ្រាវនិងការអភិវឌ្ឍន៍) R&D) និងផ្តល់ការលើកទឹកចិត្តនិងជំរុញបរិយាកាសអំណោយផលសម្រាប់ភាពជាដៃគូរវាងវិស័យឯកជននិងសាធារណៈ)PPPs) ឆ្ពោះទៅរកការបង្កើនផលិតភាពនិងគុណភាព | ទទួលស្គាល់ថា“វិស័យឯកជន”ក៏រួមបញ្ចូលទាំងសហគ្រាសធុនតូចនិងមធ្យមផងដែរ |
| | | 1.6បង្កើនការវិនិយោគក្នុងសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍រួមគ្នានិងពង្រឹងកិច្ចសហការក្នុងតំបន់ដែលមានស្រាប់ក្នុងចំណោមAMS | ធ្វើការស្រាវជ្រាវរួមគ្នាលើយេនឌ័រនិងកសិកម្មនៅAMS |

| | | | |
|---|---|---|---|
| ST3 | ធានាសន្តិសុខស្បៀងអាហារសុវត្ថិភាពអាហារូបត្ថម្ភល្អប្រសើរនិងការចែកចាយប្រកបដោយសមធម៌ | 3.1ផ្សព្វផ្សាយការអប់រំអាហារូបត្ថម្ភនិងការយល់ដឹងអំពីរបបអាហារដែលមានសុខភាពល្អរបស់អ្នកប្រើប្រាស់។ | ផ្តោតលើស្ត្រីជាភ្នាក់ងារនៃការផ្លាស់ប្តូរសម្រាប់ការគាំទ្ររបបអាហារដែលមានសុខភាពល្អនិងការទទួលទានអាហារដែលសំបូរសារធាតុចិញ្ចឹម |
| ST4 | បង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុគ្រោះធម្មជាតិនិងភាពតក់ស្លុតផ្សេងៗ | 4.1.1កសាងសមត្ថភាពរបស់ATWGARDក្នុងការសរសេរសំណើរដើម្បីស្វែងរកការគាំទ្រថវិកាពីមូលនិធិអាកាសធាតុ។ | កសាងសមត្ថភាពរបស់ពួកគេដើម្បីបញ្ចូលយេនឌ័រទៅក្នុងសំណើ។ |
| | | 4.4ធ្វើសមាហរណកម្មបញ្ហាយេនឌ័រទៅក្នុងវិស័យកសិកម្មអាកាសធាតុការនេសាទនិងព្រៃឈើដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រីចំពោះផលប៉ះពាល់សង្គមនិងសេដ្ឋកិច្ចនៃគ្រោះធម្មជាតិនិងការប្រែប្រួលអាកាសធាតុ។ )SPFAF ៤(៧. | កសាងសមត្ថភាពដើម្បីបញ្ចូលយេនឌ័រទៅក្នុងកម្មវិធីនិងគោលនយោបាយដែលមានស្រាប់និងថ្មី។ |
| ST6 | ពង្រឹងវិធីសាស្ត្ររួមគ្នារបស់អាស៊ានលើបញ្ហាអន្តរជាតិនិងតំបន់ | 6.2បង្ហាញពីជំហររួមរបស់អាស៊ានលើបញ្ហាដែលប៉ះពាល់ដល់វិស័យFAFនៅក្នុងតំបន់និងអន្តរជាតិផ្សេងៗ | ការចូលរួមរបស់ ATWGARD ដើម្បីបង្ហាញពីជំហររួមរបស់អាស៊ានលើបញ្ហាដែលប៉ះពាល់យេនឌ័រនិងFAF |

## ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានក្នុងវិស័យបសុសត្វ ២០១៦-២០២០

| ការជំរុញយុទ្ធសាស្ត្រ | ពណ៌នា | សកម្មភាព | កិច្ចអន្តរាគមន៍យេនឌ័រ |
|---|---|---|---|
| ST1 | លើកកម្ពស់ពាណិជ្ជកម្មក្នុងនិងក្រៅតំបន់របស់អាស៊ានលើទំនិញបសុសត្វ។ | 1.1<br>ធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយនិងបរិយាកាសបទប្បញ្ញត្តិដើម្បីជួយសម្រួលដល់ពាណិជ្ជកម្ម | តស៊ូមតិអាជ្ញាធរសមស្របដើម្បីដោះស្រាយបញ្ហាសង្គមនិងជាពិសេសយេនឌ័រនៃការផលិតនិងការកែច្នៃសត្វចិញ្ចឹម។ |
| ST2 | ការគ្រប់គ្រងជំងឺនិងសុវត្ថិភាពម្ហូបអាហារដើម្បីពង្រីកពាណិជ្ជកម្មនិងការពារសុខភាពមនុស្ស | | |
| ST3 | ការកែលម្អផលិតភាពប្រកបដោយនិរន្តរភាពការគ្រប់គ្រងធនធានធម្មជាតិនិងផលប៉ះពាល់សត្វចិញ្ចឹមទៅលើបរិស្ថាននិងការប្រែប្រួលអាកាសធាតុ | 3.1.<br>វិស័យបសុសត្វមានផលិតភាពនិងមានការប្រកួតប្រជែងនៅទូទាំងពិភពលោក | ធ្វើការស្រាវជ្រាវអំពីផលប៉ះពាល់យេនឌ័រលើវិស័យបសុសត្វដោយសារការប្រែប្រួលអាកាសធាតុ |
| ST4 | គាំទ្រដល់អ្នកចិញ្ចឹមសត្វខ្នាតតូចសម្រាប់កាត់បន្ថយភាពក្រីក្រសន្តិសុខស្បៀងអាហារូបត្ថម្ភនិងសមភាពយេនឌ័រ។ | 4.1.បសុសត្វបម្រើជាមាគ៌ាដ៏សំខាន់មួយសម្រាប់កាត់បន្ថយភាពក្រីក្របង្កើនអាហារូបត្ថម្ភនិងសមភាពយេនឌ័រ។ | សកម្មភាព ៤.១.១<br>។ធ្វើឱ្យគោលនយោបាយតស៊ូមតិចំពោះឥណទានបសុសត្វដែលមានអត្រាការប្រាក់ទាបអាចចូលទៅដល់ជនក្រីក្រជាពិសេសស្ត្រីតាមរយៈឥណទានខ្នាតតូច SMEនិងកម្មវិធីផ្សេងទៀតដែលរៀបចំឡើងសម្រាប់ការកាត់បន្ថយភាព. ក្រីក្រ។ |

| | | | |
|---|---|---|---|
| | | | |

## ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហប្រតិបត្តិការ អាស៊ានក្នុងវិស័យដំណាំ

## ២០១៦-២០២០

| ការជំរុញយុទ្ធសាស្ត្រ | ពណ៌នា | សកម្មភាព | កិច្ចអន្តរាគមន៍យេនឌ័រ |
|---|---|---|---|
| ST1 | លើកកម្ពស់បរិមាណនិងគុណភាពនៃការផលិតប្រកបដោយនិរន្តរភាពបច្ចេកវិទ្យាបៃតង ប្រព័ន្ធគ្រប់គ្រងធនធាននិងកាត់បន្ថយការខាតបង់មុននិងក្រោយប្រមូលផល | 1.6ផ្តល់យន្តការស្ថាប័ននិងការលើកទឹកចិត្តសមស្របសម្រាប់ PPPក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍និងការសាយភាយបច្ចេកវិទ្យាសហការជាមួយវិស័យឯកជនដើម្បីកំណត់អាទិភាពទូទាត់បញ្ហាស្រាវជ្រាវខ្ពស់ហើយប្រើវាជាបណ្តាញសម្រាប់បង្កើតបច្ចេកវិទ្យានិងការសាយភាយ | សហការជាមួយវិស័យឯកជនដើម្បីបង្កើត“ករណីជំនួញសម្រាប់សមភាពយេនឌ័រនៅក្នុងអនុវិស័យដំណាំលូតលាស់លឿននេះ” |
| ST2 | បង្កើនការសម្របសម្រួលពាណិជ្ជកម្មការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងការចូលទីផ្សារ | | អនុលោមតាមសេចក្តីប្រកាសទីក្រុងប៊ូណូសអ៊ែររបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពីស្ត្រីនិងពាណិជ្ជកម្មឆ្នាំ ២០១៧ ធានាឱ្យមានការចូលរួមស្មើគ្នាក្នុងពាណិជ្ជកម្មបញ្ហាដែលទាក់ទង ។ |
| ST3 | ធានាសន្តិសុខស្បៀងអាហារសុវត្ថិភាពអាហារូបត្ថម្ភល្អប្រសើរនិងការចែកចាយប្រកបដោយសមធម៌ | 3.4 ធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងនិងអាហារូបត្ថម្ភតាមរយៈការធ្វើពិពិធកម្មប្រភពអាហារនិងការពង្រឹងគុណភាពនិងភាពខុសគ្នានៃការផលិតម្ហូបអាហារនិងការធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់តម្លៃអាហារ | ចូលរួមជាមួយក្រុមស្ត្រីនិងសហគ្រាសធុនតូចនិងមធ្យមដើម្បីតស៊ូមតិដើម្បីធ្វើពិពិធកម្មប្រភពអាហារ។ |
| ST4 | បង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុគ្រោះធម្មជាតិនិងផលប៉ះពាល់ផ្សេងៗ | 4.2លើកកម្ពស់ការទទួលបានធនធានហិរញ្ញវត្ថុអាកាសធាតុដើម្បីគាំទ្រដល់កសិកម្មឆ្លាតវៃអាកាសធាតុ/ | កសាងសមត្ថភាពលើការបញ្ចូលយេនឌ័រទៅក្នុងសំណើដើម្បីទទួលបានហិរញ្ញវត្ថុអាកាសធាតុ។ |
| ST5 | ជួយអ្នកផលិតខ្នាតតូចដែលមានបញ្ហាប្រឈមនឹងធនធាននិងសហគ្រាសខ្នាតតូចនិងមធ្យមដើម្បីកែលម្អផលិតភាពបច្ចេកវិទ្យានិងគុណភាពផលិតផលដើម្បីបំពេញតាមស្តង់ដារទីផ្សារពិភពលោកនិងបង្កើនការប្រកួតប្រជែង ។ | | ស្រដៀងគ្នាទៅនឹង SPAដែរការតស៊ូមតិចំពោះឥណទានការប្រាក់ទាបអាចចូលទៅដល់ជនក្រីក្រជាពិសេសស្ត្រីតាមរយៈឥណទានខ្នាតតូច SMEនិងកម្មវិធីផ្សេងទៀតដែលបង្កើតឡើងសម្រាប់ការកាត់បន្ថយភាពក្រីក្រ។ |
| ST6 | ពង្រឹងវិធីសាស្ត្ររួមគ្នារបស់អាស៊ានលើបញ្ហាអន្តរជាតិនិងតំបន់ | 6.2បង្ហាញជំហររួមរបស់អាស៊ានលើបញ្ហាដែលជះឥទ្ធិពលដល់វិស័យដំណាំនៅតំបន់និងអន្តរជាតិ | សម្របសម្រួលនិងពង្រឹងជំហររួមគ្នាលើបញ្ហាយេនឌ័រនៅតាមវេទិកាអន្តរជាតិនិងតំបន់ |

# ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហប្រតិបត្តិ
# ការអាស៊ានក្នុងវិស័យជលផល
# ២០១៦-២០២០

| ការជំរុញយុទ្ធសាស្ត្រ | ពណ៌នា | សកម្មភាព | កិច្ចអន្តរាគមន៍យេនឌ័រ |
|---|---|---|---|
| ST1 | លើកកម្ពស់បរិមាណនិងគុណភាពនៃការផលិតដោយបច្ចេកវិទ្យាប្រកបដោយនិរន្តរភាព<br><br>បច្ចេកវិទ្យាបែតងប្រព័ន្ធគ្រប់គ្រងធនធាននិងកាត់បន្ថយការខាតបង់មុននិងក្រោយប្រមូលផល | 1.1.4.ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដើម្បីកំណត់និងដោះស្រាយតម្រូវការវិនិយោគ ផលិតកម្មប្រកបដោយនិរន្តរភាពប្រព័ន្ធគ្រប់គ្រងការវិនិយោគក្រោយពេលប្រមូលផល | ការចូលរួមស្មើភាពយេនឌ័ររបស់អ្នកនេសាទនិងមេដឹកនាំស្ត្រីនៃវិស័យឯកជននៅក្នុងការពិភាក្សារបស់ភាគីពាក់ព័ន្ធ |
| | | 1.4.1ធ្វើបច្ចុប្បន្នភាពនិងពង្រឹងគោលនយោបាយជលផលក្របខ័ណ្ឌច្បាប់និងស្ថាប័នតាមរយៈការពិគ្រោះយោបល់និងការចូលរួមពីទីភ្នាក់ងាររដ្ឋាភិបាលវិស័យឯកជនអ្នកនេសាទសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធដទៃទៀត យោងទៅ]POA 7] | ធានាឱ្យមានការចូលរួមស្មើភាពគ្នារវាងស្ត្រីនិងបុរស |
| ST2 | បង្កើនការសម្របសម្រួលពាណិជ្ជកម្មការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងការចូលទីផ្សារ | 2.4.2លើកកម្ពស់ភាពជាដៃគូយុទ្ធសាស្ត្រជាមួយសហគមន៍ជលផលអាស៊ាននិងអង្គការកសិករ អ្នកផលិតអ្នកប្រើប្រាស់និងពាណិជ្ជករ។ | រួមបញ្ចូលក្រុមស្ត្រីនិងអង្គការកសិករ |
| ST3 | ធានាសន្តិសុខស្បៀងអាហារសុវត្ថិភាពអាហារូបត្ថម្ភល្អប្រសើរនិងការចែកចាយប្រកបដោយសមធម៌ | 3.2.2.សហការជាមួយស្ថាប័នពាក់ព័ន្ធរបស់អាស៊ានក្នុងការបញ្ចប់និងអនុវត្តគោលនយោបាយសុវត្ថិភាពម្ហូបអាហារអាស៊ានពន្លឿនការបង្កើតស្តង់ដារសុវត្ថិភាពម្ហូបអាហារ | សហការជាមួយស្ថាប័នអាស៊ានដូចជាការចូលរួមស្មើភាពយេនឌ័រ ASCC លើគោលនយោបាយសុវត្ថិភាពម្ហូបអាហារ |
| ST4 | បង្កើនភាពធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុគ្រោះធម្មជាតិនិងផលប៉ះពាល់ផ្សេងៗ | 4.1.1.លើកកម្ពស់កិច្ចសហការរវាងAMS ពាក់ព័ន្ធនិងដៃគូ | ធ្វើការស្រាវជ្រាវអំពីបញ្ហាយេនឌ័រនិងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យជលផល។ |

| | | | |
|---|---|---|---|
| ST5 | ជួយអ្នកផលិតខ្នាតតូចដែលប្រឈមបញ្ហាធនធាន និងសហគ្រាសខ្នាតតូចនិងមធ្យមដើម្បីកែលម្អផលិតភាពបច្ចេកវិទ្យានិងគុណភាពផលិតផលដើម្បីបំពេញតាមស្តង់ដារទីផ្សារពិភពលោកនិងបង្កើនការប្រកួតប្រជែង។ | 5.3.1ធានាថាកម្មវិធីនិងគោលនយោបាយជាតិស្តីពីជលផលនិងវារីវប្បកម្មផ្តោតលើទិដ្ឋភាពសង្គមសេដ្ឋកិច្ចនិងបរិស្ថាននៃជលផលនិងវារីវប្បកម្មប្រកបដោយនិរន្តរភាពដើម្បីធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងជីវភាពរស់នៅការងារនិងការកាត់បន្ថយភាពក្រីក្រ | សង្កត់ធ្ងន់លើបញ្ហាយេនឌ័រនៅពេលពិភាក្សាអំពីបញ្ហាសង្គម។ |
| ST6 | ពង្រឹងវិធីសាស្ត្ររួមគ្នារបស់អាស៊ានលើបញ្ហាអន្តរជាតិនិងតំបន់ដែលប៉ះពាល់ដល់វិស័យ FAF | 6.2.1.លើកកម្ពស់ការសន្ទនាក្នុងចំណោម AMSដើម្បីបង្កើតជំហររួមស្តីពីបញ្ហាជលផលដែលជះឥទ្ធិពលដល់តំបន់អាស៊ាន | រួមបញ្ចូលមុខតំណែងរួមរបស់ AMS នៅក្នុងបញ្ហាយេនឌ័រនៅក្នុងជលផល។ |

## ផែនការសកម្មភាពយុទ្ធសាស្ត្រ (SPA) សម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានក្នុងវិស័យព្រៃឈើ

## ២០១៦-២០២៥

| ការជំរុញយុទ្ធសាស្ត្រ | ពណ៌នា | សកម្មភាព | កិច្ចអន្តរាគមន៍យេនឌ័រ |
|---|---|---|---|
| ST1 | លើកកម្ពស់បរិមាណនិងគុណភាពនៃការផលិតប្រកបដោយនិរន្តរភាពបច្ចេកវិជ្ជាបៃតងប្រព័ន្ធគ្រប់គ្រងធនធាននិងកាត់បន្ថយការខាតបង់មុននិងក្រោយប្រមូលផល | 1.3.ការពង្រឹងការគ្រប់គ្រងព្រៃឈើពាក់ព័ន្ធនឹងការរស់នៅរបស់សហគមន៍ក្នុងនិងជុំវិញព្រៃដើម្បីនិរន្តរភាពព្រៃឈើនិងភាពរុងរឿងរបស់ប្រជាជន។ | ខណៈពេលកំពុងពិនិត្យមើលការរៀបចំការកាន់កាប់តាមប្រពៃណីនិងតាមច្បាប់សូមគូសបញ្ជាក់ពីបញ្ហាសមភាពនិងសមធម៌យេនឌ័រ |
| | | 1.4ការទទួលយកការអនុវត្តការគ្រប់គ្រងប្រកបដោយនិរន្តរភាពសម្រាប់ផលិតផលព្រៃឈើដែលមិនមែនជាឈើដូចជារុក្ខជាតិឱសថ ផ្តៅ ឬស្សី។ល។ | នៅក្នុងសហគមន៍ភាគច្រើនស្ត្រីមានចំណេះដឹងជ្រៅជ្រះអំពីផលិតផលព្រៃឈើដែលមិនមែនជាឈើដូច្នេះវាជាការចាំបាច់ដើម្បីចូលរួមជាមួយពួកគេក្នុងការរៀបចំការអនុវត្តការគ្រប់គ្រងប្រកបដោយនិរន្តរភាព។ |
| ST2 | បង្កើនការសម្របសម្រួលពាណិជ្ជកម្មការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងការចូលទីផ្សារ | 2.2.ការពង្រឹងកិច្ចសហការក្នុងការអភិវឌ្ឍផលិតផលព្រៃឈើ។ | ធ្វើការវាយតម្លៃខ្សែច្រវ៉ាក់តម្លៃលើផលិតផលព្រៃឈើដោយមានកញ្ចក់ឆ្លុះយេនឌ័រ។ចូលរួមស្ត្រីក្នុងការវាយតម្លៃដើម្បីទាញយកប្រយោជន៍ពីចំណេះដឹងនិងជំនាញរបស់ពួកគេសម្រាប់ការអភិវឌ្ឍន៍ផលិតផលព្រៃឈើ។ |

| | | | |
|---|---|---|---|
| ST3 | ធានាសន្តិសុខស្បៀងអាហារសុវត្ថិភាពអាហារូបត្ថម្ភល្អប្រសើរនិងការចែកចាយប្រកបដោយសមធម៌ | 3.1ការធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ | វាយតម្លៃផលប៉ះពាល់និងហានិភ័យយេនឌ័រនៃផែនការកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងការសម្របខ្លួននៅក្នុងវិស័យព្រៃឈើ។ |
| ST4 | បង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុគ្រោះធម្មជាតិនិងផលប៉ះពាល់ផ្សេងៗ | 4.2.បង្កើនការចែករំលែកបទពិសោធន៍និងមេរៀនដែលបានរៀន។ | សម្របសម្រួលការរៀនសូត្រឆ្លងដែនក្នុងចំណោម AMSក្នុងវិស័យយេនឌ័រព្រៃឈើនិងការប្រែប្រួលអាកាសធាតុក្រុមការងារអាស៊ានស្តីពីព្រៃឈើសង្គម |
| ST5 | ជួយអ្នកផលិតដែលប្រឈមបញ្ហាធនធានដែលរារាំងអ្នកផលិតនិងសហគ្រាសធុនតូចនិងមធ្យមដើម្បីកែលម្អផលិតភាពបច្ចេកវិទ្យានិងគុណភាពផលិតផលដើម្បីបំពេញតាមស្តង់ដារទីផ្សារពិភពលោកនិងបង្កើនការប្រកួតប្រជែងស្របតាមផែនការគោលនយោបាយអាស៊ានស្តីពីការអភិវឌ្ឍន៍ សហគ្រាសធុនតូចនិងមធ្យម។ | 5.2.ការធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្ររួមរបស់អាស៊ានក្នុងការដោះស្រាយបញ្ហាព្រៃឈើតំបន់និងអន្តរជាតិ។ | អនុម័តនិងកំណត់ជំហររួមរបស់អាស៊ានស្តីពីយេនឌ័រនិងព្រៃឈើនិងជះឥទ្ធិពលដល់លទ្ធផលនៃការពិភាក្សានៅក្នុងវេទិកាអន្តរជាតិនិងតំបន់ |

## ក្របខណ្ឌសន្តិសុខស្បៀងរួមរបស់អាស៊ាន(AIFS) និងផែនការសកម្មភាពយុទ្ធសាស្ត្រ លើសន្តិសុខស្បៀងក្នុងតំបន់អាស៊ាន (២០១៥-២០២០)

| ការជំរុញយុទ្ធសាស្ត្រ | ពណ៌នា | សកម្មភាព | កិច្ចអន្តរាគមន៍យេនឌ័រ |
|---|---|---|---|
| ST1 | ពង្រឹងសន្តិសុខស្បៀងរួមទាំងការរៀបចំជំនួយសង្គ្រោះបន្ទាន់ / ខ្វះខាត | 1.2. និរន្តរភាពនៃច្រវ៉ាក់ផ្គត់ផ្គង់ស្បៀងអាហារជាមួយនឹងការពង្រឹងដល់ឧស្សាហកម្មគ្រាប់ពូជ | បង្កើតវេទិកាសម្រាប់ចែករំលែកបញ្ហាសង្គមនិងយេនឌ័រនៅក្នុងឧស្សាហកម្មគ្រាប់ពូជ |
| ST2 | ជំរុញទីផ្សារម្ហូបអាហារដែលមានអំណោយផលនិងពាណិជ្ជកម្ម | 2.1.3.ប្រមូលទិន្នន័យនិងធ្វើការវិភាគដើម្បីគាំទ្រដល់កិច្ចប្រជុំបច្ចេកទេសAFSRB ដូចជាសេណារីយ៉ូគោលនយោបាយសម្រាប់ទីផ្សារស្រូវការវាយតម្លៃផលប៉ះពាល់នៃការធ្វើកិច្ចសន្យាលើកសិករខ្នាតតូចនិងការសិក្សាពាក់ព័ន្ធ | ការវិភាគអាចផ្តោតលើបញ្ហាយេនឌ័រនៅលើទីផ្សារម្ហូបអាហារនិងពាណិជ្ជកម្មជាពិសេសលើអង្ករនិងត្រី។ |

| | | | |
|---|---|---|---|
| ST3 | ពង្រឹងប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងអាហាររួមបញ្ចូលគ្នាដើម្បីធ្វើការព្យាករណ៍រៀបចំផែនការនិងត្រួតពិនិត្យការផ្គត់ផ្គង់និងការប្រើប្រាស់សម្រាប់ទំនិញស្បៀងជាមូលដ្ឋាន | 3.1.3.ធ្វើការវាយតម្លៃតាមកាលកំណត់អំពីស្ថានភាពនិងទស្សនវិស័យអង្ករនិងទំនិញស្បៀងសំខាន់ៗដទៃទៀតនៅក្នុងអាស៊ាន | ការវាយតម្លៃនេះក៏អាចរួមបញ្ចូលបញ្ហាសង្គមនិងយេនឌ័រដែលទាក់ទងនឹងអង្ករនិងទំនិញម្ហូបអាហារសំខាន់ៗដទៃទៀតនៅក្នុងអាស៊ាន |
| ST4 | ជំរុញផលិតកម្មស្បៀងប្រកបដោយនិរន្តរភាព | 4.1.7.ពង្រីកនិងលើកកម្ពស់ចំណេះដឹងរបស់កសិករលើសពីវិស័យកសិកម្មដើម្បីរួមបញ្ចូលអាជីវកម្មនិងសហគ្រិនភាព | ការអភិវឌ្ឍន៍សមត្ថភាពលើបញ្ហាយេនឌ័រក្នុងវិស័យកសិ-ពាណិជ្ជកម្មនិងភាពជាសហគ្រិន |
| ST5 | ជម្រុញឱ្យមានការវិនិយោគកាន់តែច្រើនលើវិស័យម្ហូបអាហារនិងឧស្សាហកម្មដែលមានមូលដ្ឋានលើកសិកម្មដើម្បីបង្កើនសន្តិសុខស្បៀង | 5.1.1.រៀបចំផែនទីបង្ហាញផ្លូវសម្រាប់ខ្សែច្រវាក់តម្លៃក្នុងតំបន់ដែលផ្តោតលើតម្រូវការកសិកម្ម | ការចូលរួមស្មើគ្នានៃក្រុមសហគមន៍ស្ត្រីនិងសហគ្រាសធុនតូចនិងមធ្យមក្នុងការរៀបចំផែនទីបង្ហាញផ្លូវ។ |
| ST6 | កំណត់និងដោះស្រាយបញ្ហាដែលទាក់ទងនឹងសន្តិសុខស្បៀង | 6.1.1.ធ្វើការសិក្សាអំពីផលប៉ះពាល់រយៈពេលវែងនៃការអភិវឌ្ឍន៍ថាមពលជីវសាស្ត្រនិងសន្តិសុខស្បៀងនៅ AMS | ការសិក្សាគួរតែរួមបញ្ចូលផ្នែកសង្គមការពាក់ព័ន្ធនឹងយេនឌ័រផងដែរ។ |
| ST7 | ប្រើប្រាស់ព័ត៌មានអាហារូបត្ថម្ភដើម្បីគាំទ្រដល់សន្តិសុខស្បៀងនិងគោលនយោបាយកសិកម្មផ្អែកលើភស្តុតាង | 7.1.1.ធ្វើសិក្ខាសាលាថ្នាក់តំបន់ដើម្បីកំណត់កំណត់ព័ត៌មានអាហារូប/ត្ថម្ភនិងសូចនាករសំខាន់ៗវិធីសាចងក្រងដែលត្រូ/ស្រ្តក្នុងការប្រមូលវការសម្រាប់ការត្រួតពិនិត្យសន្តិសុខស្បៀងទៀងទាត់និងការអភិវឌ្ឍន៍គោលនយោបាយ | សិក្ខាសាលានេះគួរតែបញ្ចូលបញ្ហាយេនឌ័រនៅក្នុងអាហារូបត្ថម្ភ។ |
| ST8 | កំណត់គោលនយោបាយស្ថាប័ននិងយន្តការអភិបាលកិច្ចសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្មលើកកម្ពស់អាហារូបត្ថម្ភនៅ AMS | 8.1.ការយល់ដឹងនិងការទទួលស្គាល់ពីសារៈសំខាន់នៃអាហារូបត្ថម្ភដោយភាគីពាក់ព័ន្ធសំខាន់ៗនៃម្ហូបអាហារកសិកម្មនិងព្រៃឈើ | ការចូលរួមរបស់ស្ត្រីមានសារៈសំខាន់នៅក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹងទាំងនេះ។ |
| ST9 | អភិវឌ្ឍន៍និងពង្រឹងគោលនយោបាយអាហារូបត្ថម្ភស្បៀងអាហារកសិកម្មនិងព្រៃឈើនិងពង្រឹងសមត្ថភាពសម្រាប់ការអនុវត្តការត្រួតពិនិត្យនិងវាយតម្លៃរបស់ពួកគេ | 9.1.គោលនយោបាយនិងកម្មវិធីអភិវឌ្ឍន៍ស្បៀងអាហារការលើកកម្ពស់អាហារូបត្ថម្ភកសិកម្មនិងព្រៃឈើបានបង្កើតនិងពង្រឹង | បង្កើតសមត្ថភាពក្នុងការបញ្ចូលយេនឌ័រទៅក្នុងគោលនយោបាយនិងកម្មវិធីស្បៀងអាហារ-កសិកម្មនិងព្រៃឈើ |